# ទានកថា

ព្រះបាឡាត់ឃោសនាគ

## ហែម-ចៀវ

(ជោតញ្ញាណោ)

អាចារ្យ

សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ប្រែរៀបរៀង

INSTITUT BOUDDHIQUE

ភ្នំពេញ

ព.ស. ២៥០៩

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ធាតុកថា

ព្រះបាឡាត់ឃោសនាគ ហែម-ចៀវ (ជោតញ្ញាណោ)

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

អាចារ្យ

សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ប្រែរៀបរៀង

ព្រះករុណាជាម្ចាស់ជីវិតទ្រង់ឡាយព្រះហស្តលេខាព្រះរាជទានព្រះរាជានុញ្ញាត
ឲ្យបោះពុម្ពតាមសេចក្ដីដែលកុងស៊ីយ៍សេនាបតីក្រាបបង្គំទូល

បោះពុម្ពលើកទី ៦

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០៩

# អារម្ភកថា

សៀវភៅនេះ ព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ ចាងហ្វាងវង់សាលាបាលីជាន់ខ្ពស់ ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បម្រុងនឹងរៀបរៀងដោយព្រះអង្គលោក តាមសេចក្តីអារាធនារបស់លោកគ្រូចៅអធិការ **ឌិត-ឌិម** ប៉ុន្តែលោកមានការងារច្រើនលើសលុបពេក រកឱកាសនឹងផ្ចៀតធ្វើឲ្យហើយទាន់ពេលមិនបាន លោកក៏ដាក់ភារៈប្រគល់ឲ្យខ្ញុំធ្វើ ខ្ញុំក៏ទទួលរៀបរៀងតាមកម្លាំងសតិបញ្ញារបស់ខ្លួន ។

សៀវភៅនេះខ្ញុំកំណត់ឲ្យឈ្មោះ *ទានកថា* ចែកជា ៤ ពួក ដើម្បីឲ្យងាយសង្កេតដល់សាធុជនអ្នកមើល :

ទី ១ ឈ្មោះ *ទានប្បកាសនកថា* និយាយប្រកាសបើកលំអានអំពីការឲ្យទាន,

ទី ២ ឈ្មោះ *ទានវិភជនកថា* និយាយអំពីចំណែកឈ្មោះទាន,

ទី ៣ ឈ្មោះ *ទានលក្ខណកថា* និយាយអំពីលក្ខណៈ ឬ របៀបឲ្យទាន,

ទី ៤ ឈ្មោះ *ទានានិសំសកថា* និយាយអំពីអានិសង្សរបស់ទាន ។

កាលដែលចាប់ផ្ដើមរៀបរៀងធម៌នេះ មកប្រទះលើកាលដែលខ្ញុំកំពុងមានកិច្ចរវល់ខ្លាំង ៗ រកវេលានឹងធ្វើឲ្យហើយរហ័សមិនបាន ខ្ញុំក៏រំលែកឲ្យលោកអាចារ្យ **ហាយ** ក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ឲ្យលោកជួយរៀបរៀងត្រង់កថាទី ១ និងកថាទី ៤ ដើម្បីឲ្យបានសម្រេចឆាប់រហ័សទាន់ពេល ។

ឯគម្ពីរដែលខ្ញុំដកស្រង់យកធម៌មករៀបរៀងក្នុងសៀវភៅនេះ គឺ គម្ពីរមង្គលត្ថទីបនី ១ អង្គុត្តរនិកាយព្រមទាំងអដ្ឋកថា ១ មជ្ឈិមនិកាយ ១ ខន្ធកវិន័យមហាវគ្គ ១ យោជនាដីកាវិន័យ ១ ទុតិយសមន្តប្បាសាទិកាអដ្ឋកថា ១ ទាំងសេចក្ដី

សម្រាយដែលលោកអ្នកប្រាជ្ញបានប្រែរៀបរៀងទុករួចមកហើយ ខ្លះ យកមករួបរួម ។ លុះខ្ញុំរៀបរៀងរួចស្រេចហើយ ទើបយកទៅប្រគេនព្រះតេជព្រះគុណព្រះពុទ្ធឃោសាចារ្យ សូមឲ្យលោកផ្ទៀងផ្ទាត់ លោកក៏ទទួលផ្ទៀងឲ្យដោយសព្វគ្រប់ ឃើញថាត្រឹមត្រូវហើយ ។

ដោយកម្លាំងព្យាយាម ដែលខ្ញុំរៀបរៀង **ឈានកថា** នេះ សូមឲ្យព្រះពុទ្ធសាសនារុងរឿងអស់កាលជានិច្ច ! ទាំងពួកពុទ្ធបរិសទ្យដែលបានសិក្សានិងប្រតិបត្តិតាម ក៏សូមឲ្យបរិបូណ៌ដោយសេចក្ដីចម្រើន ៗ សព្វវេលា ! ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ថ្ងៃច័ន្ទ ៣ កើតខែអស្សុជ ឆ្នាំថោះឯកស័ក ព.ស. ២៤៨២

ត្រូវនឹងថ្ងៃ ១៦ អុកតូប្រ ១៩៣៩ ។

ព្រះបាឡាត់ឃោសកាត ហែម-ចៀវ

អាចារ្យសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

# បញ្ជីមាតិកា

## ទានប្បកាសនកថា


| | ទំព័រ | បន្ទាត់ |
|---|---|---|
| ប្រភេទនៃពួកសត្វ | ១ | ៣ |
| ទាន ៣ យ៉ាងមានករុណាទានជាដើម | ៤ | ៦ |
| ភោគសម្បត្តិដែលទៅជាទោសជាគុណ | ៥ | ១២ |
| អំពីពាក្យថា ទានៈនិងចាគៈ : | ៨ | ១១ |


## ទានវិភជនកថា


| | | |
|---|---|---|
| ប្រភេទរបស់ទាន ៣ យ៉ាង | ១៣ | ១២ |
| អាមិសទាន | ១៥ | ១៣ |
| អំពីបច្ច័យ ៤ យ៉ាង | ១៦ | ២ |
| អំពីទានវត្ថុ ១០ យ៉ាង | ″ | ១១ |
| បាដិបុគ្គលិកទាន ១៤ | ១៩ | ៦ |
| សង្ឃគតទក្ខិណាទាន ៧ | ២១ | ២ |
| សប្បុរិសទាន ៥ យ៉ាង | ២២ | ២ |
| សប្បុរិសទាន ៥ យ៉ាងទៀត | ២៤ | ៤ |
| កាលទាន ៥ យ៉ាង | ២៦ | ១៤ |
| អសប្បុរិសទាន ៥ យ៉ាង | ២៧ | ៨ |
| អសម្មតទាន ៥ យ៉ាង | ៣០ | ២ |
| ធម្មទាន | ៣១ | ៦ |


## ទានលក្ខណកថា


| | | |
|---|---|---|
| ទក្ខិណាវិសុទ្ធិ ៤ យ៉ាង | ៣៤ | ៩ |
| អង្គរបស់អ្នកឲ្យទាន ៣ យ៉ាង | ៣៦ | ៤ |
| អង្គរបស់អ្នកទទួល ៣ យ៉ាង | ″ | ១៣ |
| ទានដ៏ប្រពៃមានស្ថាន ៧ ប្រការ | ៣៨ | ២ |
| ចីវរប្បច្ច័យ | ៤០ | ២ |

# បញ្ជីមាតិកា


| | ទំព័រ | បន្ទាត់ |
|---|---|---|
| ឈ្មោះចីវរ ៤ យ៉ាង . . . . . . . . . . . . . . | ៤០ | ៩ |
| អង្គចីវរ ៩ យ៉ាង . . . . . . . . . . . . . . | ៤១ | ៦ |
| ឃ្លាតចីវរ . . . . . . . . . . . . . . | ៤៦ | ៤ |
| បិណ្ឌបាតប្បច្ច័យ . . . . . . . . . . . . . . | ៤៧ | ៨ |
| ពង្គហត្ថបាស ៥ យ៉ាង . . . . . . . . . . . . . . | ៤៩ | ៧ |
| ទេយ្យវត្ថុឆាពីដកាចឬភ្លួតតាច . . . . . . . . . . . . . . | ៥២ | ៧ |
| សមណកប្ប ៥ ប្រការ . . . . . . . . . . . . . . | ៥៣ | ២ |
| សេនាសនប្បច្ច័យ . . . . . . . . . . . . . . | " | ១៣ |
| ពូក ៥ យ៉ាង . . . . . . . . . . . . . . | ៥៥ | ៦ |
| គិលានភេសជ្ជប្បច្ច័យ . . . . . . . . . . . . . . | " | ១២ |
| កាលិក ៤ យ៉ាង . . . . . . . . . . . . . . | ៥៧ | ៣ |
| ទឹក ៨ ប្រការ . . . . . . . . . . . . . . | ៥៨ | ៤ |
| ទឹក ៨ ប្រការទៀត . . . . . . . . . . . . . . | " | ១១ |
| ភេសជ្ជៈ ៥ យ៉ាង . . . . . . . . . . . . . . | ៥៩ | ១០ |


## ទានានិសង្សកថា


| | | |
|---|---|---|
| បុគ្គលអ្នកឲ្យទានបែកតាមភូមិមាន ៣ . . . . . . . . . . | ៦២ | ៤ |
| អានិសង្សនៃអាមិសទាន ៥ យ៉ាង . . . . . . . . . . | ៦៤ | ១៤ |
| អានិសង្សនៃធម្មទាន ៥ យ៉ាង . . . . . . . . . . | ៦៨ | ៥ |


## សេចក្ដីស្រង់របស់ក្រុមជំនុំគិបព្រះត្រៃបិដក


| | | |
|---|---|---|
| អំពីកន្សែងចីវរ . . . . . . . . . . . . . . | ៧០ | ៦ |
| អំពីស្មៀងចីវរ . . . . . . . . . . . . . . | ៧២ | ៥ |
| សម្រេចសេចក្ដីអំពីកន្សែងចីវរ . . . . . . . . . . . . . . | ៧៣ | ១៣ |
| តម្រូវចីវរបញ្ចុណ្ណ . . . . . . . . . . . . . . | ៧៥ | ១ |
| អង្គចីវរ ៩ យ៉ាង . . . . . . . . . . . . . . | ៧៧ | ២ |

## នមត្ថុ រតនត្តយស្ស

សត្វទាំងឡាយក្នុងលោកនេះ កាលបើពោលតាមប្រភេទនៃពួកសត្វ មានច្រើនពួកច្រើនឈ្មោះជាអនេក តែបើពោលដោយរួបរួម បានដល់សត្វតែ ១ ពួកដែលមានជីវិតជាទីស្រឡាញ់តែប៉ុណ្ណោះ; ពួកសត្វទាំងអស់សុទ្ធតែមានសេចក្ដីសុខទុក្ខជាប់ទាក់ទងដោយរាងកាយ ឬថាមានរាងកាយជាទីអាស្រ័យនៅនៃសេចក្ដីសុខទុក្ខ ដូចគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស ។ ជីវិតដែលតាំងនៅបានក៏ព្រោះអាស្រ័យរាងកាយ, ការគ្រប់គ្រងចិញ្ចឹមរាងកាយដោយអាហារផ្សេង ៗ ក៏ឈ្មោះថាគ្រប់គ្រងជីវិត ។ ការរក្សាជីវិតរបស់មនុស្សទាំងអស់ជាភារៈយ៉ាងធ្ងន់បំផុត, សាច់ ឈាម ស្បែក សរសៃ ពណ៌សម្បុរដែលចម្រើនស្រស់បស់ឡើងបានក៏ព្រោះអាស្រ័យអាហារ, កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចម្រើនជាប់តទៅក៏ឈប់ចម្រើន; រាងកាយទាំងមូលក៏ស្វិតស្រពោនថយចុះ

ទៅ, ទាំងជីវិតសោតក៏តាំងនៅបានដោយក្រ ។ៗ អាហារជារបស់សំខាន់សម្រាប់បម្រុងជីវិតឲ្យប្រព្រឹត្តទៅ សមដូចបាលីថា សព្វេ សត្តា អាហារដ្ឋិតិកា "ពួកសត្វរាល់រូបមានជីវិតតាំងនៅបានព្រោះអាហារ" ។ វត្ថុដទៃក្រៅអំពីអាហារនោះទៀត ជនជាតិមនុស្សត្រូវមានលំនៅសម្រាប់ជាទីជ្រកកោន សំពត់សម្រាប់ស្លៀកដណ្ដប់, ថ្នាំសម្រាប់កែរោគក្នុងគ្រាដែលត្រូវការ; វត្ថុអម្បាលនេះ សុទ្ធតែជារបស់សម្រាប់ឧបត្ថម្ភទប់ទល់ជីវិតដោយពិត បើប្រាសចាករបស់ណាមួយ ជីវិតរមែងតាំងនៅបានដោយលំបាក ។ ជនជាតិមនុស្សលុះតែមានចំណេះវិជ្ជា ឬកម្លាំងកាយកម្លាំងបញ្ញាបរិបូណ៌ទើបអាចស្វែងរកអាហារបានបរិភោគ រកទីអាស្រ័យនៅនិងគ្រឿងប្រើប្រាស់សម្រាប់ជួយជីវិតបានគ្រប់គ្រាន់ល្អ ។ ចំណែកមនុស្សដែលគ្មានចំណេះវិជ្ជា ខ្សោយកម្លាំង ឬឥតគុណសម្បត្តិណាមួយក្នុងខ្លួនក៏មិនអាចរក្សាជីវិតរាងកាយ ឲ្យរស់នៅតាមទំនើងខ្លួនឯងបានឡើយ, មនុស្សបែបនេះត្រូវអាស្រ័យពឹងផ្អែកនឹងអ្នក

ដទៃ ឲ្យគេជួយចិញ្ចឹមជីវិតរបស់ខ្លួនជាដរាប គឺឲ្យជួយប្រាប់ឧបាយក្នុងការចិញ្ចឹមជីវិត, ការរក្សារាងកាយ និងការរក្សាចិត្តឲ្យតាំងនៅដោយល្អ ; ព្រោះថាមនុស្សទាំងអស់ក្នុងលោករមែងមានវាសនា ឬ គុណសម្បត្តិនិងកម្លាំងផ្សេង ៗ គ្នា, បំណែករាងមនុស្សដែលខ្សត់ខ្សោយវាសនានិងគុណសម្បត្តិ ឬខ្សោយកម្លាំងកាយ និងសម្ងំនៅតាមទំនើងខ្លួនឯងមិនបាន ត្រូវធ្វើសមាគមគប់រកមនុស្សដែលសម្បូណ៌វាសនា និងគុណសម្បត្តិឬកម្លាំងកាយ ឲ្យជួយណែនាំបង្ហាត់បង្រៀន ជួយជ្រោមជ្រែងដោយទ្រព្យរបស់ឬភោជនាហារសម្រាប់ចិញ្ចឹមជីវិត ។ មនុស្សដែលមានវាសនា និងគុណសម្បត្តិខ្ពង់ខ្ពស់ ក៏ត្រូវតែទទួលអភិបាលរក្សាមនុស្សដែលនៅតូចទន់ខ្សោយ ឬ ឋោកទាបជាងខ្លួនដោយកិច្ចប្រៀនប្រដៅនិងទ្រព្យសម្បត្តិជាដើមទុន ឬ អាហារសម្រាប់បរិភោគរាល់ថ្ងៃជាដរាប ដូចមាតាបិតាជាប្រធាននៃបុត្តធីតា ។ ការឲ្យអាហារឬគ្រឿងប្រើប្រាស់គ្រប់យ៉ាង នេះជាកល្យាណប្បវេណី, ជាទំនៀមមួយដ៏វិសេស ជាប់មកតាំងអំពី

មុនពុទ្ធកាល តាមបាលីលោកហៅថា **ទានៈ** ប្រែថា ការឲ្យ ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមានចិត្តអាណិតទោរទន់ទៅរកមនុស្សសត្វដទៃ ហើយបានឲ្យគ្រឿងបរិភោគដោយសេចក្ដីអាណិតតែម្យ៉ាង មិនអាស្រ័យយកកម្លាំងប្រើប្រាស់, ការឲ្យទានដូច្នេះ ហៅថា **ករុណាទាន** ។ បុគ្គលខ្លះយល់ច្បាស់ក្នុងគុណូបការៈ ឬគុណសម្បត្តិណាមួយរបស់លោកអ្នកមានគុណ មានមាតាបិតាគ្រូអាចារ្យឬលោកអ្នកទ្រទ្រង់នូវគុណមានសីលគុណជាដើម ក៏ធ្វើទានចំពោះលោកអ្នកមានគុណនោះ, ការឲ្យទានដូច្នេះ ហៅថា **បូជាទាន** ឬ **បដិការទាន** ។ មនុស្សពួកខ្លះជាអ្នកមានចិត្តធូរទូលាយ ចង់ឲ្យប្រយោជន៍ ឲ្យសេចក្ដីសុខសេចក្ដីចម្រើនដល់អ្នកដទៃ ដែលជាញាតិសាលោហិតឬមិត្តសំឡាញ់ ឬក៏ ជាមនុស្សរួមជាតិជាមួយគ្នាដែលល្មមទទួលអំណោយការសង្គ្រោះបាន ហើយចែកទ្រព្យសម្បត្តិជាដើមទុនក្ដី គ្រឿងបរិភោគគ្រឿងប្រើប្រាស់ក្ដី ដើម្បីទំនុកបម្រុងជួយជាកម្លាំងសង្គ្រោះឲ្យកើតប្រយោជន៍ស្មើមុខគ្នាឡើង, ការឲ្យទានដូច្នេះ ហៅថា **អនុគ្គហទាន** ឬ **សង្គហទាន** ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងឡើងក្នុងលោកហើយ ព្រះអង្គបានស្រាវជ្រាវសំដែងពន្យល់ពុទ្ធបរិសទ្យអំពីទានៈ និងចាគៈ ដោយន័យច្រើនជាអនេក បានទាំងទ្រង់ប្រៀនប្រដៅវិធីក្នុងការបរិច្ចាគទាន ដោយសព្វគ្រប់ សឹងមានប្រាកដមកក្នុងស្ថានធម៌ផ្សេងៗ គឺមានមក ក្នុងអនុបុព្វីកថាខ្លះ ក្នុងបារមី-ធម៌ខ្លះ ក្នុងសប្បុរិសប្បញ្ញត្តិខ្លះ ក្នុងបុញ្ញកិរិយាវត្ថុខ្លះ ក្នុងទសពិធរាជធម៌ខ្លះ ក្នុងអរិយទ្រព្យខ្លះ ក្នុងអធិដ្ឋានធម៌ខ្លះ ក្នុងសង្គហធម៌ខ្លះ ក្នុងសម្បរាយិកត្ថធម៌ខ្លះ ក្នុងឧបនិស្សយធម៌ខ្លះ ។ គុណសម្បត្តិគឺការបំពេញទាននេះ ចាត់ជាមង្គលមួយដ៏ប្រសើររបស់សប្បុរស ។

៙ ភោគសម្បត្តិទាំងអស់ក្នុងលោកនេះរមែងកើតទៅជាទោសក៏មាន ទៅជាគុណក៏មាន ។ ភោគសម្បត្តិណាដែលនៅក្នុងដៃរបស់មនុស្សល្ងង់ខ្លៅ ជាអ្នកមិនយលប្រយោជន៍ដ៏ធំទូលាយក្នុងកាលឥឡូវនេះនិងកាលខាងមុខ ទ្រព្យសម្បត្តិនោះ នឹងត្រឡប់ទៅជាទោសដល់ខ្លួនជាម្ចាស់វិញដោយពិត, ជួនកាលក៏

គ្រាន់តែជារបស់កណ្ដាលៗ មិនសម្រេចប្រយោជន៍ធំទូលាយតទៅទៀតក៏មាន, ដូចអ្នកមានប្រទីបសម្រាប់អុជបំភ្លឺ តែបើម្ចាស់មិនបានអុជបំភ្លឺទេ ក៏មិនមានប្រយោជន៍អ្វីអំពីប្រទីបនោះឡើយ ។

ភោគសម្ប័ទណាដែលនៅក្នុងដៃរបស់មនុស្សអ្នកចេះដឹងជាអ្នកយល់ប្រយោជន៍ដ៏ធំទូលាយ, ទ្រព្យសម្បត្តិនោះ នឹងត្រឡប់ទៅជាគុណដល់ខ្លួនជាម្ចាស់វិញជាប្រាកដ ។ ឯទ្រព្យសម្បត្តិដែលថាជាគុណ ឬ ជាប្រយោជន៍នោះ គឺសម្រាប់ចាយវាយទៅចិញ្ចឹមខ្លួន ទំនុកបម្រុងមាតាបិតាគ្រូអាចារ្យ និងអន្តោជនពាហិរជនគឺបុត្តភរិយាទាសកម្មករ, ធ្វើទក្ខិណាទានចំពោះភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនា ដើម្បីជាបុញ្ញនិធិរបស់ខ្លួន, ធ្វើពលី ៥ យ៉ាងមានញាតិពលីជាដើម ។ ការប្រើប្រាស់ទ្រព្យសម្បត្តិបែបនេះ ឈ្មោះថា ពង្រីកឬបណ្ដុះទ្រព្យសម្បត្តិឲ្យបានទៅជាគុណជាប្រយោជន៍ចម្រើនរុងរឿងធំទូលាយទាំងឥធលោក និងបរលោក ។ មួយទៀត ជនណា ជាគ្រហស្ថ មានប្រាជ្ញា

គ្រប់គ្រងផ្ទះកាលបើបានលៃលកទ្រព្យធនឲ្យទានទុកជាកំណប់ ជននោះឈ្មោះថាបានជញ្ជូនទ្រព្យសម្បត្តិទុកដាក់ឲ្យផុតបាក សេចក្តីអន្តរាយដើម្បីជាប្រយោជន៍តទៅ សមដូចព្រះពុទ្ធភាសិតថា

អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច
នីហរេថេវ ទានេន ទិន្នំ ហោតិ សុនីហតំ

(សេចក្តីថា) កាលបើផ្ទះត្រូវភ្លើងឆាបឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូនទ្រព្យសម្បត្តិ មានភាជនៈ (ជាដើម) ចេញពីផ្ទះ, ទ្រព្យណាដែលគេប្រញាប់ជញ្ជូនចេញផុត ភ្លើងឆេះមិនបាន ទ្រព្យនោះរមែងបានទៅជាប្រយោជន៍របស់គេតទៅ យ៉ាងណាមិញ; សត្វលោកដែលត្រូវភ្លើងគឺជរានិងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឲ្យផុតអំពីផ្ទះគឺរាងកាយដោយការឲ្យទាន ព្រោះថាទានដែលគេឲ្យហើយនោះឯងឈ្មោះថាបានជញ្ជូនទ្រព្យទុកដោយល្អ មិនឲ្យភ្លើងឆេះបាន ក៏យ៉ាងនោះដែរ ។

សេចក្ដីនេះបំភ្លឺឲ្យឃើញថា កាលបើផ្ទះគឺរាងកាយត្រូវភ្លើងគឺជរានិងមរណៈឆាបឆេះ ទ្រព្យសម្បត្តិដែលនៅក្នុងកំណាត់របស់មច្ឆរិយៈ ដែលគេមិនបានប្រញាប់ជញ្ជូនយកចេញដោយការបំពេញទានទេ ក៏មុខជានឹងត្រូវភ្លើងជរានិងមរណៈឆេះខ្ទេចខ្ទីជាមួយនឹងរាងកាយ ទៅជារបស់ឥតប្រយោជន៍មិនបាន ។ ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់សំដែងពន្យល់អំពី **ទានៈ** និង **ចាគៈ** ជារឿយៗដើម្បីឲ្យកើតប្រយោជន៍ដ៏ធំទូលាយអំពីទ្រព្យសម្បត្តិនោះៗ ដូចសេចក្ដីដែលបានសំដែងមកនេះឯង ។

៩ លំដាប់ពីនេះនឹងពោលអំពីពាក្យថា **ទានៈ** និង **ចាគៈ** ដោយសង្ខេប ។ ពាក្យទាំងពីរនេះបើសំដៅយកសេចក្ដី ឃើញប្រាកដថាផ្សេងៗគ្នា តែបើពោលតាមលក្ខណៈក៏ស្រដៀងៗគ្នា; តាមសេចក្ដីអធិប្បាយ ចំពោះពាក្យថា **ទានៈ** នេះ មានន័យ ៤ យ៉ាង ដូចសេចក្ដីដែលត្រូវសំដែងតទៅនេះ

១– ទាន: ការឲ្យវត្ថុណាមួយដែលនៅជាប់ចំពាក់ដោយមច្ឆរិយៈ ឬឲ្យដោយស្ទាក់ស្ទើរមិនជ្រះស្រឡះចាកមច្ឆរិយៈ ឬក៏ឲ្យតាមទម្លាប់ទំនៀមត្រកូលរបស់គេ មិនមែនជាកិច្ចអស្ចារ្យចម្លែកជាងត្រកូលដែលធ្លាប់ធ្វើមកប៉ុណ្ណោះ ។

២– ទាន: ការឲ្យដែលជាប់ដោយតណ្ហា គឺបុគ្គលអ្នកឲ្យទានប្រាថ្នាយកសិរីសួស្តី និងផលប្រយោជន៍មកខ្លួនវិញចំពោះសាមិសសុខក្នុងភពនេះឬភពមុខ ។

៣– ទាន: ការឲ្យមិនសមគួរ គឺបុគ្គលណាមានទ្រព្យសម្បត្តិច្រើន មានវត្ថុដ៏ថ្លៃថ្លាច្រើន លុះត្រូវការបាត់បែងទានក៏បាត់បែងដោយរើសរលាបស្អុយស្អើង និងវត្ថុដ៏ថោកទាបតាមធម្មតា, **ទាន** របស់បុគ្គលនោះ ឈ្មោះថាជាទានមិនសមតាមសក្តិតាមកម្លាំងនៃទ្រព្យសម្បត្តិដែលខ្លួនមាន ។

៤– ទាន: ការឲ្យចំពោះមុខបដិគ្គាហកៈ អ្នកទទួលផ្ទាល់ដែលជាបុគ្គលខ្ពស់ខ្ពង់ដោយគុណធម៌និងទ្រព្យសម្បត្តិ

ឬខ្ពង់ខ្ពស់ដោយគុណធម៌; នេះជាសេចក្ដីអធិប្បាយរបស់ពាក្យ ហិ **ឧទានៈ** ។

បំណែកខាង **ចាគៈ** ក៏មានសេចក្ដីអធិប្បាយបែកចេញជាន័យ ៤ យ៉ាងគឺ

១– *ចាគៈ* ការលះវត្ថុណាមួយចំពោះបដិគ្គាហកៈ ដើម្បីលះបង់ឬសង្កត់សង្កិននូវលោភៈ និងមច្ឆរិយៈ ឲ្យស្រាលស្ដើងចាកសន្ដាន គឺចំណាយទ្រព្យធនដើម្បីទុកជាអលង្ការ ឬជាកល្យាណវត្តរបស់ចិត្ត មិនបណ្ដោយឲ្យចិត្តជ្រលក់ជាប់នៅក្នុងកិលេស ។

២– *ចាគៈ* ការលះឲ្យ ដែលមិនជាប់ចំពាក់ដោយតណ្ហា គឺឲ្យដោយបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើចិត្តឲ្យបរិសុទ្ធ បើកឱកាសឲ្យបញ្ញារបស់ខ្លួន មានកម្លាំងលូតលាស់ចំរើនឡើងផង ដើម្បីប្រយោជន៍និងសេចក្ដីសុខថ្កុំថ្កើងជាតម្រាប់ដល់យុវជនជាន់ក្រោយផង ដូចយ៉ាងការចំណាយទ្រព្យសម្បត្តិទំនុក

បម្រុងព្រះពុទ្ធសាសនា កសាងសេនាសនៈ លើកថ្នល់ សង់ស្ពាន ជីកអណ្ដូងទឹក សង់សាលាបម្រុងការសិក្សាឬសាលាសំណាក់ទុកសម្រាប់ជាសាធារណៈ មិនបានចំពោះបដិគ្គាហកៈ ។

៣- *ចាគៈ* ការលះឲ្យវត្ថុដ៏ច្រើនក្រៃលែង ឬខ្ពង់ខ្ពស់លើសវិស័យរបស់មនុស្សសាមញ្ញក្នុងលោកគួរឲ្យស្ញើច ដែលរាប់ថាជាការបរិច្ចាគយ៉ាងខ្ពង់ខ្ពស់បំផុតកម្រអ្នកផងយកតម្រាប់តាមបាន ដូចយ៉ាងមហាបរិច្ចាគរបស់ព្រះពោធិសត្វ ។

៤- *ចាគៈ* ការលះកាត់អាល័យក្នុងជីវិតនិងសេចក្ដីសុខក្នុងទ្រព្យសម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្វះស្វែងរកឧបាយជួយជ្រោមជ្រែងមនុស្សក្នុងលោក ឬលះបង់ទ្រព្យសម្បត្តិដើម្បីរោយរាយចែកចាយឲ្យទៅជាប្រយោជន៍ផ្ដល់សេចក្ដីសុខសេចក្ដីចំរើនរុងរឿងដល់មហាជន ទុកជាកេរ្ដិ៍ដំណែលតទៅ ។

ពាក្យថា *ទានៈ* និង *ចាគៈ* មានសេចក្ដីផ្សេងគ្នាដូចពណ៌នាមកនេះឯង ។ កាលបើសង្កេតមើលតាមដំណើរ

សេចក្ដីក្នុងន័យទាំងនោះគង់ឃើញច្បាស់ថា **ចាគៈ** មានកម្លាំងជាង **ទានៈ** ឬថាជាធម៌ខ្ពង់ខ្ពស់ផ្សាយរស្មីរុងរឿងលេចសេចក្ដីទូលាយល្អជាង **ចាគៈ** ។ មួយទៀត **ទានៈ** និង **ចាគៈ** នេះបើពោលតាមលក្ខណៈរួបរួម ក៏គឺការឲ្យ ការបែករំលែកទ្រព្យសម្បត្តិបំពោះសត្វឬបុគ្គលដទៃប៉ុណ្ណោះឯង, តែបើនិយាយតាមហេតុផលវិញ **ទានៈ** ជាឈ្មោះបរិក្ខារវត្ថុដែលគេត្រូវឲ្យ, **ចាគៈ** ជាឈ្មោះចេតនាដែលជាតួចេតសិកសម្រាប់លះ, **ទានៈ** បាត់ជាផល, **ចាគៈ** បាតជាហេតុ អាស្រ័យគ្នាដូចដួងព្រះអាទិត្យនិងពន្លឺរស្មីនៃព្រះអាទិត្យ ។ មួយវិញទៀត **ទានៈ** ដូចជាផ្លែផ្កាដែលលេចចេញចាកដើមឬទង, **ចាគៈ** ដូចជាដើមឬទងនៃរុក្ខជាតិនិងវល្លិជាតិ ជាបច្ច័យឲ្យកើតផ្លែផ្កា ឬថា**ចាគៈ**ទុកដូចជាដើមពូជមុនដំបូង, **ទានៈ** ទុកដូចជាផ្លែផ្កាដែលកើតអំពីពូជខាងដើម ដូច្នេះវិញក៏បាន ។

ចប់ទានប្បកាសនកថាតែប៉ុណ្ណេះ ។

# ទានចិត្តជនកថា

ការឲ្យទានជាបវេណីកិច្ចដ៏ប្រសើររបស់កល្យាណជន ជាបរិយាដ៏វិសេសរបស់បណ្ឌិតទាំងឡាយ មានពោធិសត្វជាដើម ដែលលោកតែងតែបំពេញទុកជាឧបនិស្ស័យរៀងរាល់ជាតិមិនដែលរំលង ។

កម្រៃនៃការឲ្យទាននេះ រមែងនាំបណ្ដាលឲ្យសម្រេចប្រយោជន៍ គឺសេចក្ដីល្អ សេចក្ដីសុខ និងសេចក្ដីចម្រើន ដល់បុគ្គលអ្នកធ្វើនោះជាច្រើនប្រការ ។

ធម្មទេសនា ដែលព្រះលោកនាថទ្រង់ត្រាស់សំដែងអំពីទាននោះ មានច្រើនជាអនេក ហួសវិស័យនឹងពណ៌នាឲ្យសព្វគ្រប់បាន តែបើកំណត់ឈ្មោះតាមប្រភេទដែលផ្សេងគ្នាដោយចេតនា និង ទេយ្យវត្ថុ មាន ៣ យ៉ាងគឺ

១– *ចាគចេតនា ទាន* ចេតនាដែលលះទេយ្យវត្ថុឲ្យដល់បុគ្គលដទៃ ឈ្មោះថា **ទាន,**

២_ *វិរតិ ទានំ* ចេតនាដែលវៀរវែលងចាកអំពើអា-ក្រក់មានវៀរចាកបាណាតិបាតជាដើម ឈ្មោះថា **ទាន**,

៣- *ទេយ្យធម្មោ ទានំ* ទេយ្យធម៌គឺវត្ថុដែលគេត្រូវលះឲ្យដល់បុគ្គលដទៃ ឈ្មោះថា **ទាន** ។

បណ្ដា**ទាន**ទាំង ៣ យ៉ាងនេះ លើកវិរតិទាន លេញមិនអធិប្បាយក្នុងទីនេះទេ ព្រោះលោកចាត់ជា អភយទាន បានដល់ការកាន់សីល ៥ ឯណោះហោយឡែក, ឯ ចាគចេតនាទាន និងទេយ្យធម្មទាន ទាំងពីរនេះ ពិតជាមានឈ្មោះផ្សេងគ្នាតាមប្រ-ភេទមែន ប៉ុន្តែជាធម្មជាតមិនអាចនឹងញ៉ាំងកុសលឲ្យសម្រេចបានដោយឡែកពីគ្នាឡើយ ព្រោះថា បើបុគ្គលមានតែចេតនាបម្រុងលះឲ្យ តែគ្មានទេយ្យវត្ថុនឹងលះឲ្យ ក៏ធ្វើជាទានមិនកើតឬមានទេយ្យវត្ថុល្មមលះឲ្យដែរ តែគ្មានចេតនាសម្រាប់លះឲ្យក៏ធ្វើឲ្យកើតជា ទាន មិនបាន, លុះតែមាន ចេតនា និង ទេយ្យវត្ថុព្រមគ្នាទាំងពីរ ទើបបុគ្គលធ្វើឲ្យសម្រេចកើតទៅជា **ទាន** ឡើងបាន ។

ឥឡូវនេះ នឹងលើកយកទានពីរប្រការ ដែលមានមកក្នុងគម្ពីរអង្គុត្តរនិកាយទុកនិបាតមករៀបរៀងទុកជាគោលដើមតាមលំអានពុទ្ធភាសិតថា ទ្វេមានិ ភិក្ខវេ ទានានិ ។ កតមានិ ទ្វេ? អាមិសទានញ្ច ធម្មទានញ្ច ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានំ ។ (ប្រែថា) ម្នាលភិក្ខុទាំងឡាយ ទានមានពីរប្រការ ទានទាំងពីរប្រការតើដូចម្តេចខ្លះ? (ទានទាំងពីរប្រការនោះ) គឺ

១_ *អាមិសទានំ* ការឲ្យអាមិសៈជាទាន,

២_ *ធម្មទានំ* ការឲ្យធម៌ជាទាន ។

ម្នាលភិក្ខុទាំងឡាយ, បណ្ដាទានទាំងពីរប្រការនេះ, ធម្មទានជាទានប្រសើរជាងអាមិសទាន ។

## អាមិសទាន

ទាយកទាំងឡាយដែលប្រកបដោយសទ្ធាបានលះទេយ្យវត្ថុគឺបច្ច័យ ៤ យ៉ាងនិងទានវត្ថុ ១០ យ៉ាងឲ្យដល់សួមទាំងពួងហៅថា អាមិសទាន ។

## បច្ច័យ ៤ យ៉ាងនោះគឺ

១_ ចីវរប្បច្ច័យ ចីវរ មានស្បង់ ចីពរ សង្ឃាដី ជាដើម,

២_ បិណ្ឌបាតប្បច្ច័យ ភោជនាហារ មានបាយ ជាដើម,

៣_ សេនាសនប្បច្ច័យ ទីសម្រាប់ដេក អង្គុយ មានកុដិ សាលា ជាដើម,

៤_ គិលានភេសជ្ជប្បច្ច័យ ថ្នាំជាបច្ច័យសម្រាប់ រក្សាជម្ងឺ មានថ្នាំត្រាំដោយទឹកមូត្រជាដើម ។

## ទានវត្ថុ ១០ យ៉ាងនោះគឺ

១- អន្នំ គ្រឿងបរិភោគគឺបង្អែមឬបំអាបគ្រប់មុខ,

២- បានំ ទឹក ៨ ប្រការ មានទឹកដែលគេធ្វើដោយផ្លែស្វាយជាដើម,

៣– *វត្ថំ* សំពត់ស្លៀកនិងសំពត់ដណ្ដប់ជាដើម,

៤– *យានំ* យានដែលញ៉ាំងដំណើរឲ្យសម្រេច មាន រថជាដើម មានស្បែកជើងជាទីបំផុត,

៥– *មាលា* ផ្កាឈើគ្រប់យ៉ាងដែលគេក្រងស្រេចហើយ ឬមិនទាន់ក្រង,

៦– *គន្ធំ* គ្រឿងក្រអូបដែលជាគន្ធជាតមានក្លិនទាំងអស់ និងគ្រឿងផ្សំផ្សំផល់គ្រឿងក្រអូប ដែលគេកិនក្ដី មិនបាន កិនក្ដី,

៧– *វិលេបនំ* គ្រឿងលាប គឺវត្ថុសម្រាប់លាបស្បែក ខាងក្រៅ ឲ្យគួរជាទីត្រេកអរនិងជាទីពេញចិត្ត,

៨– *សយនំ* ទីដេក កន្លែងសម្រាប់ដេកអង្គុយ មាន គ្រែ តាំង និងចៀមព្រំជាដើម,

៩– *អាវសថំ* ទីនៅ គឺគេហដ្ឋានជាទីនៅឬជ្រកកោន

សម្រាប់ការពារនូវសេចក្ដីអន្ដរាយ សេចក្ដីលំបាក មានខ្យល់និងកម្ដៅថ្ងៃជាដើម,

១០- *បទីបេយ្យំ* ប្រទីបនិងគ្រឿងប្រទីប វត្ថុសម្រាប់ទំនុកបម្រុងដល់ប្រទីប មានអំបែងនិងប្រឆេះគោមបង្គៀងជាដើម ។

**អាមិសទាន**នេះ ព្រះសម្មាសម្ពុទ្ធជាធម្មស្សាមីទ្រង់ត្រាស់សំដែងញែកឈ្មោះតាមលក្ខណៈ ឬកិច្ចរបស់ទាននោះមានច្រើនប្រការ , បើនឹងស្រូតរូតស្រង់យកទានឲ្យបានច្រើនមករៀបរៀងក្នុងទីនេះក៏បាន ប៉ុន្តែពេលមិនល្មម, ហេតុដូច្នេះនឹងលើកយកតែ **បាដិបុគ្គលិកទាន** ១ **សង្ឃគតាទក្ខិណាទាន** ១ **សប្បុរិសទាន** ១ **អសប្បុរិសទាន** ១ **អសម្មតទាន** ១ **កាលទាន** ១ ទាំង ៦ ឈ្មោះនេះមករៀបរៀងក្នុងទីនេះ ព្រោះទានប៉ុណ្ណោះទុកដូចជាផ្ការ ឬជាឆ្អឹងដែលពុទ្ធសាសនិកជនទាំងឡាយតែងត្រូវការធ្វើជាញឹកញាប់ជាងទានឯទៀត ៗ ។

ទានដែលទាយកឲ្យចំពោះមុខបុគ្គលមួយ ៗ តាមសេចក្ដីស្រឡាញ់ សេចក្ដីពេញចិត្ត ដោយតាំងចិត្តថា លោកនេះជាគ្រូអាចារ្យ អ្នកនេះជាកូនចៅ ឬថា អ្នកនេះត្រូវជាញាតិមិត្រជាដើម ហៅថា **បាដិបុគ្គលិកទាន** ។

*បាដិបុគ្គលិកទាននេះ មាន ១៤ យ៉ាងគឺ*

១_ ទាន ចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ,

២_ ទាន ចំពោះព្រះបច្ចេកពុទ្ធ,

៣_ ទាន ចំពោះព្រះអរហន្ត ជាសាវ័ករបស់តថាគត,

៤_ ទាន ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះនូវអរហត្តផល,

៥_ ទាន ចំពោះអនាគាមិបុគ្គល,

៦_ ទាន ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះនូវអនាគាមិផល,

៧- ទាន បំពោះសកិទាគាមិបុគ្គល,

៨- ទាន បំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះនូវសកិទាគាមិផល,

៩- ទាន បំពោះសោតាបន្នបុគ្គល,

១០- ទាន បំពោះបុគ្គលដែលប្រតិបត្តិដើម្បីបានលុះនូវសោតាបត្តិផល,

១១- ទាន បំពោះបុគ្គលខាងក្រៅព្រះពុទ្ធសាសនា តែមានសេចក្តីជឿយណាយចាកកាម,

១២- ទាន បំពោះបុគ្គល ជាបុថុជ្ជនមានសីលបរិសុទ្ធ,

១៣- ទាន បំពោះបុគ្គល ជាបុថុជ្ជនទ្រុស្តសីល,

១៤- ទាន បំពោះសត្វតិរច្ឆាន ។

ទានដែលទាយកប្រគេនបំពោះសង្ឃ មិនបានបំពោះបុគ្គល ហៅថា **សង្ឃគតាទក្ខិណាទាន** ។

## សង្ឃគតាទក្ខិណាទាននេះមាន ៧ យ៉ាងគឺ

១- ទាន ចំពោះឧភតោសង្ឃ គឺទាំងភិក្ខុសង្ឃ និងភិក្ខុនីសង្ឃមានព្រះពុទ្ធជាប្រធាន,

២- ទាន ចំពោះឧភតោសង្ឃ ក្នុងកាលដែល ព្រះតថាគតបរិនិព្វានហើយ,

៣- ទាន ចំពោះតែភិក្ខុសង្ឃ,

៤- ទាន ចំពោះតែភិក្ខុនីសង្ឃ,

៥- ទាន ចំពោះភិក្ខុដែលគេនិមន្តយកអំពីសំណាក់ឧភតោសង្ឃ,

៦- ទាន ចំពោះភិក្ខុដែលគេនិមន្តយកអំពីសំណាក់ភិក្ខុសង្ឃ,

៧- ទាន ចំពោះភិក្ខុនីដែលគេនិមន្តយកអំពីសំណាក់ភិក្ខុនីសង្ឃ,

បណ្ដាទានទាំងពីរចំណែកនេះ **សង្ឃគតាទក្ខិណាទាន** មានផលានិសង្សច្រើនជាង **បាដិបុគ្គលិកទាន** ។

## សប្បុរិសទានមាន ៥ យ៉ាងគឺ

១- សទ្ធាយ ទានំ ទេតិ ឲ្យទានដោយសទ្ធាគឺ ឲ្យដោយចិត្តជឿកម្មនិងផលរបស់កម្មជាក់ប្រាកដថា អំពើគឺការឲ្យទាននេះ ជាអំពើមិនសូន្យសោះអសារឥតការឡើយ ប្រាកដជានឹងត្រឡប់បានផលជារង្វាន់មកវិញពុំខាន,

២- សក្កច្ចំ ទានំ ទេតិ ឲ្យទានដោយគោរព គឺ គោរពទេយ្យវត្ថុដែលត្រូវលះឲ្យ និងគោរពបដិគ្គាហកៈអ្នកទទួល; គោរពទេយ្យវត្ថុនោះ ត្រូវសំអាតទេយ្យវត្ថុដោយផ្ចិតផ្ចង់ មិនធ្វើខ្ជីខ្ជាតាមតែបាន, ឯគោរពបដិគ្គាហកៈនោះ ត្រូវសំដែងសេចក្តីរាប់រកបដិគ្គាហកៈដោយសេចក្តីស្មោះស្មើ មិនសំដែងអាការទ្រមឹងទ្រមើយ គឺត្រូវនិមន្តឬអញ្ជើញឡើងអាសនៈដ៏សមគួរជាដើម,

៣- កាលេន ទានំ ទេតិ ឲ្យទានតាមកាលគួរ គឺឲ្យតាមកាលតាមរដូវដែលគេត្រូវធ្វើ ត្រូវឲ្យ ដូចវត្ថុចូលវស្សា

និងចេញវស្សា, រដូវរងាឲ្យគ្រឿងស្លៀកដណ្តប់, រដូវក្តៅឲ្យទឹក ឬក៏ពេលដែលមានវត្ថុថ្មីប្លែកមានផ្លែឈើជាដើម,

*៤_ អនុគ្គហិតចិត្តោ ទានំ ទេតិ* ឲ្យទានដោយសេចក្តីអនុគ្រោះ គឺឲ្យដោយចិត្តអាណិតមេត្តាយ៉ាងទោរទន់ចំពោះសមណៈ ឬអ្នកក្រីក្រលំបាកដែលរងទុក្ខវេទនាដោយសេចក្តីស្រេកឃ្លានជាដើម ឲ្យបានសុខស្រួលផុតអំពីសេចក្តីទុក្ខព្រួយ ហើយឥតតាំងចិត្តថានឹងទារយកគុណបំណាច់អ្វីអំពីអ្នកទទួលទាននោះវិញឡើយ,

*៥_ អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ* ឲ្យទានដោយមិនបានតាំងចិត្តបៀតបៀនខ្លួននិងអ្នកដទៃ គឺឲ្យដោយតាំងចិត្តថា នឹងបំបាត់បង់នូវសេចក្តីលោភនិងសេចក្តីកំណាញ់ ហើយនឹងធ្វើឲ្យរស់អាសវកិលេសដែលជាមេនាំឲ្យកើតសេចក្តីទុក្ខព្រួយក្នុងវដ្តៈប៉ុណ្ណោះ, មិនបានតាំងចិត្តឲ្យអ្នកផងគេស្ងើចសរសើរថាប្រសើរជាងអ្នកដទៃឡើយ; ដែលថា

មិនបៀតបៀនខ្លួន គឺមិនឲ្យអ្នកដទៃសរសើរខ្លួន, មិនបៀតបៀនអ្នកដទៃ គឺមិនបង្អាប់បន្ទាបអ្នកដទៃ ។

សប្បុរិសទាន ៥ យ៉ាងទៀតគឺ

១- សក្កច្ចំ ទេតិ ឲ្យទានដោយសេចក្ដីគោរពចំពោះវត្ថុដែលត្រូវឲ្យ,

២- ចិត្តីកត្វា ទេតិ ឲ្យទានដោយតាំងសេចក្ដីគោរព ចំពោះវត្ថុនិងបដិគ្គាហកៈ,

៣- សហត្ថា ទេតិ ឲ្យទានដោយដៃខ្លួនឯង,

៤- អនបវិទ្ធំ ទេតិ ឲ្យទានដោយមិនបោះឲ្យ,

៥- អាគមនទិដ្ឋិកោ ទេតិ ឲ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

អធិប្បាយថា ទាយកកាលដែលធ្វើទាន បានតាំងចិត្តគោរពចំពោះវិតវត្ថុប៉ុណ្ណោះ មិនធ្វើសេចក្ដីអើពើចំពោះបុគ្គល

អ្នកទទួលទាន នោះអ្នកទទួលទាននោះមានបរិយាដូចម្ដេចក៏ ឥតរវល់ ខំប្រឹងតែគិតសម្រិតសម្រាំងទេយ្យវត្ថុដែលខ្លួនត្រូវលះឲ្យនោះឲ្យស្អាតតែម្យ៉ាង, យ៉ាងនេះហៅថា ឲ្យទានដោយសេចក្ដីគោរពចំពោះវត្ថុ ។

បុគ្គលកាលដែលធ្វើទាន បានតាំងចិត្តគោរព ចំពោះទេយ្យវត្ថុផង ចំពោះបុគ្គលអ្នកទទួលទានផងទាំងពីរយ៉ាងគឺខំប្រឹងរៀបចំចាត់ចែងទេយ្យវត្ថុនោះ ឲ្យតាលតែបានប្រសើរថ្លៃថ្លាមានរសជាតិសឆ្ងាញ់ពិសាផង ទាំងពិនិត្យមើលបុគ្គលអ្នកទទួលទានឲ្យឃើញថាមានបរិយាសណ្ដាប់ធ្នាប់ជាដើម ក៏ល្មមជាទីជ្រះថ្លា គួរកក់ក្ដៅក្នុងចិត្តបានផង ហើយក៏ឲ្យដោយសេចក្ដីគោរពចំពោះបុគ្គលអ្នកទទួល មិនព្រមសុខចិត្តប្រថុយឲ្យទៅទាំងខ្ជីខ្ជាឡើយ, យ៉ាងនេះហៅថា ឲ្យទានដោយតាំងសេចក្ដីគោរពទាំងវត្ថុនិងបដិគ្គាហកៈ ហើយទើបឲ្យ ។

ទាយក កាលដែលធ្វើទាន បានលើកទេយ្យវត្ថុឲ្យដោយដៃខ្លួនឯង មិនប្រើអ្នកដទៃឲ្យគេឲ្យទេយ្យវត្ថុរបស់ខ្លួននោះជំនួស

ខ្លួនឡើយ ដោយតាំងចិត្តថា កាលអាត្មាអញ ត្រាច់រង្គាត់ក្នុងសង្សារវដ្តមិនមានទីបំផុតដែលមិនមានដៃជើងនោះ នឹងប្រមាណមិនបានឡើយ, បើដូច្នោះ អាត្មាអញនឹងធ្វើឲ្យបានផុតចាកវដ្តសង្សារ និងជាគ្រឿងរលាស់ខ្លួនចេញចាកភព, យ៉ាងនេះហៅថា ឲ្យទានដោយដៃខ្លួនឯង ។

ទាយក កាលដែលធ្វើទាន មិនបានបោះឲ្យឬបោលឲ្យគឺហុចឲ្យដោយសេចក្តីគួរសម សំដែងអាការទន់ភ្លន់ប្រកបដោយចិត្តមេត្តា, យ៉ាងនេះហៅថា ឲ្យទានដោយមិនបានបោះឲ្យ។

ទាយក កាលដែលធ្វើទាន ដោយចិត្តជឿថាបុគ្គលអ្នកសាងទាន គង់នឹងបានផល ជាអំណោយរបស់ទាននោះមកទទួលវិញពុំខានឡើយ, យ៉ាងនេះហៅថា ឲ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

## កាលទាន ៥ យ៉ាងគឺ

១– *អាគន្តុកទានំ* ទានចំពោះអ្នកដែលទើបនឹងមកដល់ថ្មី,

២- គមិកទានំ ទានចំពោះអ្នកដែលរៀបដំណើរនឹងទៅកាន់ទីឆ្ងាយ,

៣- គិលានទានំ ទានចំពោះអ្នកជម្ងឺ,

៤- ទុព្ភិក្ខទានំ ទានក្នុងវេលាដែលកំពុងអត់ឃ្លាន,

៥- នវទានំ ទានផ្លែឈើ ឬវត្ថុដែលទើបនឹងមានដំបូង ៗ

អសប្បុរិសទាន ៥ យ៉ាងគឺ

១- អសក្កច្ចំ ទេតិ ឲ្យទានដោយសេចក្តីមិនគោរពចំពោះវត្ថុ,

២- អចិត្តី កត្វា ទេតិ ឲ្យទានដោយមិនតាំងសេចក្តីគោរព ចំពោះវត្ថុនិងបដិគ្គាហកៈ,

៣- អសហត្ថា ទេតិ ឲ្យទានដោយការមិនឲ្យដោយដៃខ្លួនឯង,

៤- *អបវិទ្ធំ ទេតិ* ឲ្យទានដោយបោះឲ្យ.

៥- *អនាគមនទិដ្ឋិកោ ទេតិ* ឲ្យទានដោយមិនជឿថានឹងបានទទួលផលវិញ ។

អធិប្បាយថា បុគ្គលដែលធ្វើទានដោយបោះឲ្យឬបោលឲ្យនោះ គឺបុគ្គលអ្នកឲ្យទាន មានចិត្តជឿថាឲ្យទានបានបុណ្យដែរ ប៉ុន្តែក្នុងពេលដែលសូមមកដល់ មិនមានចិត្តមេត្តានឹងបង់ឲ្យឬជ្រះថ្លានឹងឲ្យទានដល់សូមនោះសោះ, ដោយសារតែទាល់ហើយក៏បោះឲ្យទៅ, ទោះស្ថិតនៅក្នុងទីជិតគ្នាល្មមនឹងហុចឲ្យដោយស្រួលបាន ក៏បែរជាបោះឲ្យវិញ ឥតតាំងចិត្តយកបុណ្យឡើយ, ពុំនោះសោត ដោយសារតែមានទ្រព្យច្រើន ក៏បាចឬបោះឲ្យ ដើម្បីឲ្យអ្នកក្រីក្រប្រជែងគ្នាដណ្ដើមរើសយក និងបានមើល ហើយសើចលេងសប្បាយប៉ុណ្ណោះ ។

បុគ្គលដែលធ្វើទានដោយមិនជឿថា នឹងបានទទួលផលវិញនោះ គឺបុគ្គលដែលមិនជឿថាមានបុណ្យ មានបាប មាន

នរក មានសួគ៌ជាដើម, មនុស្សក្តី សត្វក្តី កើតឡើងល្អឯង អាក្រក់ឯង គឺតមានបុណ្យបាបអ្វីតាក់តែងឲ្យឡើយ; ដែលឲ្យទាននេះ ដោយតាំងចិត្តថា ព្រោះតែស្គាល់គ្នាហើយឲ្យទៅ ឬដោយសារមានមនុស្សមកសូមហើយ ក៏ឲ្យទៅប៉ុណ្ណោះ គឺតមានចិត្តនឹកកក់ក្តៅ ឬ នឹកសង្ឃឹមបន្តិចថានឹងបានបុណ្យអំពីទាននេះឡើយ ។

អសប្បុរិសទាននេះ មិនបានអធិប្បាយឲ្យគ្រប់ទាំង ៥ ទេ ព្រោះត្រង់បទទី ១ - ២ - ៣ នេះ មានទំនងសេចក្តីដូចគ្នានឹងសប្បុរិសទានដែរ គ្រាន់តែផ្លាស់ពាក្យថា គោរពនិងមិនគោរពប៉ុណ្ណោះ, សូមលោកអ្នកមើលសង្កេតយកសេចក្តីនេះផងចុះ; ពីត្រឹមទី ៤ - ៥ បានជាអធិប្បាយ ព្រោះមានសេចក្តីកំបាំងខ្លះ, បើមិនអធិប្បាយក្រែងពិបាកសង្កេត, ទើបអធិប្បាយមកប៉ុណ្ណោះ ។

## អសម្មតទាន ៥ យ៉ាងគឺ

១– ឥត្ថីទានំ ឲ្យស្រ្តីដល់បុរស ឲ្យបុរសដល់ស្រ្តី,

២– ឧសភទានំ បើកលែងគោឧសភ គឺគោបាឬគោឈ្មោលដល់មេគោ ឲ្យមេគោដល់គោឧសភ,

៣– មជ្ជទានំ ឲ្យទានទឹកស្រវឹង,

៤– សមជ្ជទានំ រាំនិងច្រៀងឲ្យជាទាន ឬឲ្យទានរបាំច្រៀងរាំត្លុកក្រមាប់,

៥– ចិត្តកម្មទានំ ឲ្យទានរូបគំនូរស្រ្តីនិងបុរស ដែលជារូបនាំឲ្យកើតតម្រេកត្រេកត្រអាលទៅរកកាម ។

ទានទាំង ៥ នេះលោកមិនសន្មតថាជាទានឡើយ ព្រោះលោកមិនចាត់ថាជាទានបានបុណ្យទេ ។ **អសប្បុរិសទាន** ៥យ៉ាងនិង **អសម្មតទាន** ទាំង៥យ៉ាងនេះ ពួកសាធុជនជាសប្បុរសមិនគប្បីធ្វើ ព្រោះជាទានឥតមានផលជាទីពឹងពំនាក់

ដល់ខ្លួនសោះឡើយ, គួរប្រឹងបំពេញតែទានឯទៀត មាន **សង្ឃគតាទក្ខិណាទាន** ជាដើមឲ្យបរិបូណ៌ចុះ ព្រោះជាទានមានផលជាកម្រៃជាទីពឹងដោយពិត ។

**អាមិសទាន ចប់ដោយសង្ខេប ។**

## ធម្មទាន

ការឲ្យធម៌ជាទានដល់អ្នកដទៃ ហៅថា **ធម្មទាន** បានដល់ការបង្រៀនធម៌ សំដែងធម៌ប្រាប់អ្នកដទៃ ដូចប្រាប់ថាធម៌នេះជាកុសល, ធម៌នេះជាអកុសល, ធម៌នេះប្រកបដោយទោស, ធម៌នេះមិនប្រកបដោយទោសជាដើម ឬសំដែងប្រាប់កម្មនិងផលរបស់កម្ម ឲ្យជាក់ប្រាកដក្នុងលោកនេះនិងលោកខាងមុខ ឲ្យដូចជាគេបង្អួលប្រាប់ និងសំដែងធម៌ញ៉ាំងបុគ្គលដទៃ ឲ្យងាកបែរចេញអំពីអកុសលធម៌ ហើយឲ្យតំកល់នៅក្នុងកុសលធម៌វិញ, ពុំនោះ សំដែងសច្ចធម៌ទាំង ៤ ប្រការថាធម៌នេះបុគ្គលគួរកំណត់ដឹង, ធម៌នេះគួរលះបង់, ធម៌នេះគួរធ្វើ

ឲ្យជាក់ច្បាស់, ធម៌នេះគួរចម្រើន ។ មួយយ៉ាងទៀត ការខំប្រឹងសរសេរ ចារចម្លងពុទ្ធវចនៈគឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ឬ ចំណាយទ្រព្យ កសាងគម្ពីរដីកាច្បាប់ព្រះពុទ្ធ-សាសនាទុក សម្រាប់ឲ្យសិក្សាតាមកុលបុត្ររៀនសូត្រ ឲ្យបានចេះដឹង បានប្រព្រឹត្តកាន់តាម ដើម្បីធ្វើមគ្គផលឲ្យកើតឡើងនឹងបានតវង្សព្រះពុទ្ធសាសនា ឲ្យចម្រើន តាំងនៅអស់កាលជាអង្វែងតទៅ, យ៉ាងនេះហៅថា **ធម្មទាន** ។

ធម្មទាន ចប់ដោយសង្ខេប ។

ការឲ្យទាន ជាកិច្ចដែលបុគ្គលនឹងធ្វើឲ្យបរិសុទ្ធគ្រប់គ្រាន់បានដោយកម្រជាងការកាន់សីល, ចំណែកសីលបើបុគ្គលត្រូវការកាន់ គ្រាន់តែរៀនសូត្រឲ្យចេះដឹងកិច្ចដែលត្រូវតមត្រូវវៀរប៉ុណ្ណោះជាដើម ហើយសមាទានកាន់យកសីលនោះ អំពីសំណាក់ភិក្ខុ ឬ សាមណេរជាដើមមក ទំប្រឹងប្រព្រឹត្តសង្រួមឲ្យត្រឹមត្រូវតាមច្បាប់នោះប៉ុណ្ណោះ ក៏អាចញុំាងកុសលនោះ ឲ្យសម្រេចបរិសុទ្ធបាន ឬថាសីលនេះ បុគ្គលទាំងអ្នកមានអ្នកក្រអាចធ្វើបានដូចគ្នា ព្រោះជាកុសលដែលបុគ្គលត្រូវរក្សាចំពោះវិរតិចេតនាម្នាក់ ៗ បាន មិនបាច់ជាប់បង់ធនធាន ។

ឯការធ្វើទាន លុះតែបុគ្គលមានទេយ្យវត្ថុល្មមលះធ្វើកើតទាំងបដិគ្គាហកៈអ្នកទទួលទានក៏មានផង ទើបធ្វើបាន, វេលាដែលធ្វើនោះទៀត មានកិច្ចត្រូវខ្វល់ខ្វាយក៏ច្រើន; មិនតែប៉ុណ្ណោះឡើយ, ទានក្នុងព្រះពុទ្ធសាសនានេះ, បុគ្គលត្រូវចាត់ចែងធ្វើឲ្យត្រឹមត្រូវដោយប្រពៃ តាមពុទ្ធានុញ្ញាតផងទៀត

ទើបនឹងបានផលានិសង្សច្រើនពេញលេញសមតាមបំណង, បើនឹងចេះតែធ្វើបំពានទាំងខ្វះខ្នា ដោយការមិនចេះដឹង ព្រោះអាងសក្តិយស ឬទ្រព្យសម្បត្តិច្រើន ធ្វើតាមទំនើងចិត្តចង់ ដោយញាណវិប្បយុត្ត មិនអាស្រ័យច្បាប់ព្រះពុទ្ធសាសនា ដែលមានមកក្នុងគម្ពីរដីកាជាគោលផងទេ, ទាននេះក៏មិនបានឈ្មោះថាធ្វើដោយប្រពៃឡើយ, ទាំងផលនៃទាននោះសោតក៏ខ្សោយចុះមកជាលំដាប់, សមដូចព្រះពុទ្ធដីកា ដែលមានមកក្នុងទក្ខិណាវិភង្គសូត្រសំដែងអំពី **ទក្ខិណាវិសុទ្ធិ** ៤ យ៉ាងថា

១– *ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ* ទានបរិសុទ្ធអំពីអ្នកឲ្យ, មិនបរិសុទ្ធអំពីអ្នកទទួល គឺអ្នកឲ្យមានសីលបរិសុទ្ធ មានធម៌ល្អ អ្នកទទួលទ្រុស្តសីល មានធម៌អាក្រក់,

២– *បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ* ទានបរិសុទ្ធអំពីអ្នកទទួល, មិនបរិសុទ្ធអំពីអ្នកឲ្យ គឺ

អ្នកឲ្យជាអ្នកទ្រុស្តសីល មានធម៌អាក្រក់, អ្នកទទួលមានសីលបរិសុទ្ធ មានធម៌ល្អ;

*៣–នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ* ទានមិនបរិសុទ្ធអំពីអ្នកឲ្យផង អំពីអ្នកទទួលផង គឺអ្នកឲ្យ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់, អ្នកទទួល ក៏ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា;

*៤_ ទាយកតោចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច* ទានបរិសុទ្ធអំពីអ្នកឲ្យផង បរិសុទ្ធអំពីអ្នកទទួលផង គឺអ្នកឲ្យ ក៏មានសីលបរិសុទ្ធ មានធម៌ល្អ, អ្នកទទួល ក៏មានសីលបរិសុទ្ធ មានធម៌ល្អ ដូចគ្នាទាំងពីរខាង ។

ព្រោះហេតុនោះ ទើបមានអត្ថាធិប្បាយថា ទាន នេះ ជាកិច្ចកម្មបុគ្គលធ្វើបានដោយប្រពៃ ។ ការធ្វើទាននេះ លុះតែ

ធ្វើឲ្យប្រកបដោយអង្គ ៦ ទើបមានផលានិសង្សច្រើន, ឯអង្គ ៦ ប្រការនោះគឺ **អង្គ** ខាងអ្នកឲ្យ ៣ , **អង្គ** ខាងអ្នកទទួល ៣ ។

### *អង្គអ្នកឲ្យ ៣ យ៉ាង*

*១- បុព្វេវ ទានា សុមនោ ហោតិ* អ្នកឲ្យ មានចិត្តសោមនស្សត្រេកអរក្នុងកាលមុនឲ្យ,

*២- ទទំ ចិត្តំ បសាទេតិ* អ្នកឲ្យញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងពេលកំពុងឲ្យ,

*៣- ទត្វា អត្តមនោ ហោតិ* អ្នកឲ្យមានចិត្តត្រេកអរត្រួតថែមតាមទានដែលឲ្យរួចហើយ ។

**អង្គ** ទាំង ៣ យ៉ាងនេះ នឹងហៅថា **បុព្វចេតនា ១ មុញ្ចនចេតនា ១ អបរាបរចេតនា ១** ដូច្នេះវិញក៏បាន ។

### *អង្គអ្នកទទួល ៣ យ៉ាង*

*១- វីតរាគា វា ហោន្តិ រាគវិនយាយ វា*

បដិបន្នា បដិគ្គាហកៈអ្នកទទួលទាន អស់រាគៈ (ពីខន្ធ-សន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់រាគៈ,

*២- វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា* បដិគ្គាហកៈអ្នកទទួលទាន អស់ទោសៈ (ពី-ខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់ទោសៈ,

*៣- វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា* បដិគ្គាហកៈអ្នកទទួលទាន អស់មោហៈ (ពីខន្ធសន្តាន) ហើយ ឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់មោហៈ ។

រួម អង្គ ទាំងពីរចំណែកត្រូវជា ៦ ប្រការ ហៅថាឆឡង្គ-ទានៈ ប្រែថា **ទានប្រកបដោយអង្គ ៦** ។ ទានប្រកបដោយអង្គ ៦ ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថា ទីងបានអានិសង្សច្រើន, បុគ្គលមិនអាចនឹងគណនារាប់ថាមានចំនួនប៉ុណ្ណោះប៉ុណ្ណោះ បានឡើយ ។

មួយទៀត ដែលហៅថា ទានដ៏ប្រពៃ នោះ មានស្ថាន៧ ប្រការគឺ

១_ *តណ្ហុត្តរិយទាន* ទានដើម្បីឆ្លងចាកតណ្ហា ដែលជាគ្រឿងនាំ ឬ បណ្តើរសត្វឲ្យអន្ទោលកើតស្លាប់ក្នុងភពតូចភពធំ,

២_ *ចិត្តីការទាន* ទានដោយសេចក្តីគោរព គឺ គោរពគ្រប់ទ្វារទាំងបី ព្រមទាំងទេយ្យវត្ថុដែលត្រូវលះឲ្យ មិនឲ្យដោយអាការសោះអង្អើយ,

៣_ *ហិរោត្តប្បទាន* ទានដោយសេចក្តីខ្មាសបាប ក្តៅនឹងបាប,

៤_ *និរវសេសទាន* ទានដោយមិនគិតសំចៃទុក មិននឹកស្តាយក្រោយ,

៥_ *ទក្ខិណេយ្យទាន* ទានចំពោះទក្ខិណេយ្យ-បុគ្គល,

៦- *សោមនស្សបរិវារទាន* ទានដោយសោមនស្ស រីករាយ និងការពិចារណាឃើញប្រយោជន៍ជាក់លាក់ មិនស្រវឹងស្រវាន់ ដោយវិចិកិច្ឆានីវរណៈ,

៧- *អលង្ការបរិវារទាន* ទានជាគ្រឿងអលង្ការនិងជាបរិវារនៃចិត្ត គឺតាំងចិត្តថានឹងយកការឲ្យទានមកជាគ្រឿងប្រដាប់សម្រាប់អប់រំដាស់អរបស់ចិត្ត ជាគ្នានឹងចិត្ត ។

បំណែកបច្ច័យ ៤ យ៉ាង (តាមដំណើរសេចក្ដីក្នុងវិន័យ) បើទាយកធ្វើទានដោយបច្ច័យណាមួយចំពោះសមណៈក្នុងសាសនា ទោះជា **ធាដិបុគ្គលិកទាន** ក្ដី ជា **សង្ឃទាន** ក្ដី លុះតែធ្វើឲ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាត ល្មមគួរដល់សមណៈក្នុងសាសនាទទួលប្រើប្រាស់បាន មិនខាស់នឹងវិនយកិច្ច ទើបទាននោះមានផលច្រើន ។ បច្ច័យ ៤ យ៉ាងដែលនឹងធ្វើឲ្យត្រឹមត្រូវតាមពុទ្ធានុញ្ញាតនោះ ដូចសេចក្ដីតទៅនេះ

## ចីវរប្បច្ច័យ

សំពត់សម្រាប់បព្វជិតស្លៀកដណ្តប់ ហៅថា **ចីវរប្បច្ច័យ** ។ សង្ឃាដី, ចីពរ, ស្បង់; សំពត់ចីវរទាំង៣នេះមានពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គ ត្រង់ចីវរក្ខន្ធកៈ ដែលអនុញ្ញាតឲ្យធ្វើចីវរប្រកបដោយខណ្ឌមានបញ្ចខណ្ឌជាដើម គឺឲ្យប្រកបដោយឈ្មោះ ៤ យ៉ាង, អង្គ ៩ យ៉ាង, ត្រូវកាត់ឲ្យដាច់ចេញរួចសឹមដេរភ្ជាប់គ្នា, ធ្វើឲ្យត្រូវខ្នាត គឺកុំឲ្យធំពេកតូចពេក ។

*ឈ្មោះចីវរ ៤ យ៉ាងគឺ*

*បញ្ចខណ្ឌ ១ សត្តខណ្ឌ ១ នវខណ្ឌ ១ ឯកាទសខណ្ឌ ១* ។ សង្ឃាដី ចីពរ ស្បង់ ដែលធ្វើដោយសំពត់ ៥ ផ្ទាំង, ក្នុងផ្ទាំងមួយ ៗ មានកន្សែងពីរ ៗ គឺកន្សែងធំ១ តូច ១ ត្រូវជា ១០ កន្សែង ហៅថា **ចីវរបញ្ចខណ្ឌ** ។ ដែលធ្វើដោយសំពត់៧ផ្ទាំង មានកន្សែង ១៤ ហៅថា **ចីវរសត្តខណ្ឌ**។

ដែលធ្វើដោយសំពត់ ៩ ផ្ទាំង មានកន្សែង ១៨ ហៅថាចីវរ **នវខណ្ឌ** ។ ដែលធ្វើដោយសំពត់ ១១ផ្ទាំង មានកន្សែង២២ ហៅថា **ចីវរឯកាទសខណ្ឌ** ។ ដេរប៉ុរវក្នុងផ្ទាំងមួយ ៗ ឲ្យ មានកន្សែងពីរ ៗ ដូច្នេះ ទើបត្រូវតាមបែបក្នុងវិន័យ ។

*អន្តចីវរ ៩ យ៉ាងគឺ*

១- *កុសិ* អនុវាតជុំវិញ និងខ្នង់វែង ៗ,

២- *អឌ្ឍកុសិ* ខ្នង់ខ្លី ៗ ត្រង់បន្ទោះ ៗ,

៣- *មណ្ឌលៈ* កន្សែងធំវែង ៗ ក្នុងខណ្ឌមួយ ៗ,

៤- *អឌ្ឍមណ្ឌលៈ* កន្សែងតូចខ្លី ៗ ក្នុងខណ្ឌមួយ ៗ,

៥- *វិវដ្ដៈ* ខណ្ឌកណ្ដាល,

---

១ ក្នុងផ្ទាំងមួយ ៗ ត្រូវបែងសម្រង់ជា ៣ ភាគ, យកពីរភាគ ធ្វើជា មណ្ឌលៈ (កន្សែងធំ) គឺ បែងប្រវែងឲ្យវែងជាងអឌ្ឍមណ្ឌលៈ (ពីរភាគជាមួយភាគ), បែងយកមួយភាគធ្វើជាអឌ្ឍមណ្ឌលៈ (កន្លះភាគពីកន្សែងធំ) ។

៦- *អនុវិវដ្ដៈ* ខណ្ឌទាំងពីរខាងអមបន្ទាប់ខណ្ឌកណ្ដាល(១),

៧- *គីវេយ្យកៈ* សំពត់ដែលប៉ះឲ្យមាំត្រង់កន្លែងរុំបិទបាំងក ឬកន្សែងដែលឃ្លុំនៅត្រង់ក,

៨- *ជង្ឃេយ្យកៈ* សំពត់ដែលប៉ះឲ្យមាំត្រង់កន្លែងស្មង ឬកន្សែងដែលឃ្លុំនៅត្រង់ស្មង,

៩- *ពាហន្តៈ* ខណ្ឌបំផុតទាំងពីរខាងត្រង់កន្សែងដែលឃ្លុំនៅលើដើមដៃខាងឆ្វេង ។

ចីវរដែលថាត្រូវកាត់ឲ្យដាច់ជាកំណាត់ ៗ ហើយដេរភ្ជាប់គ្នា ទើបសមគួរដល់ភេទសមណៈនោះ មានពុទ្ធានុញ្ញាតថា អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដឹ ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកំ (ប្រែថា) «ម្នាលភិក្ខុទាំងឡាយ

១ បើចីវរសត្តខណ្ឌ មានអនុវិវដ្ដៈ ៤ គឺម្ខាងមានពីរ: ចីវរនវខណ្ឌ មានអនុវិវដ្ដៈ គឺម្ខាងមានបី: ចីវរឯកាទសខណ្ឌ មានអនុវិវដ្ដៈ ៨ គឺម្ខាងមានបួន ។

តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយប្រើ) សង្ឃាដីដែលកាត់ដាច់, ចីពរដែលកាត់ដាច់, ស្បង់ដែលកាត់ដាច់» ។ ប៉ុន្តែមានពុទ្ធានុញ្ញាតបន្ថែមមកទៀតថា បើសំពត់នោះខ្វះលែកាត់ឲ្យដាច់ទាំង ៣ ធ្វើមិនគ្រាន់ទេ, នឹងកាត់ពីរមិនកាត់មួយក៏បាន; បើកាត់ត្រឹមពីរហើយនៅតែខ្វះធ្វើមិនគ្រាន់ទៀត, នឹងកាត់តែមួយមិនកាត់ពីរក៏បាន; (មានពុទ្ធប្បញ្ញត្តិមិនឲ្យខានកាត់ទាំង៣), បើភិក្ខុប្រើប្រាស់ចីវរមិនកាត់ទាំង ៣ ត្រូវអាបត្តិទុក្កដ ។

ឯថ្នេរដែលដេរភ្ជាប់គ្នាគ្រប់ខណ្ឌគ្រប់កន្លែងជាខ្ទង់នោះត្រូវដេរជាថ្នេរតូចៗកុំឲ្យរាក់ប្រក់តម្រួតលើគ្នាជាពីរជាន់ គឺត្រង់ផ្ទៃក្នុងខ្ទង់តូច ៗ នោះត្រូវធ្វើតែមួយជាន់ស្មើគ្នាទាំងអស់ លើកតែអនុវាតជុំវិញចេញ, ដ្បិតមានពុទ្ធានុញ្ញាតថា ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ «ចីពរដេរមួយជាន់, ស្បង់ដេរមួយជាន់» ដូចគ្នា; ចំណែកខណ្ឌនិងកន្លែងរបស់ស្បង់ក៏ដូចគ្នានឹងចីពរដែរ ។ ក្នុងយោជនាដីកាវិន័យ មានសេចក្តីពន្យល់អំពីការដេរថ្នេរចីពរ និង ស្បង់នោះដោយសេចក្តី

ជាក់ច្បាស់ថា អាគិសេទុន ទិគុណំ ខណ្ឌានំ អន្តរ មាតិ គាសណ្ឋានេន ឋបិតមជ្ឈេ ធិយមជ្ឈេ ឧជ្ជុំ ។ (ប្រែថា) តាមអាទិសព្ទ គឺសព្ទដែលប្រែថា «ជាដើម» បណ្ឌិតគប្បីជ្រាបថា សំពត់ដែលគេដេរ ដោយសណ្ឋានដូចជាសណ្ឋានរបស់ប្រឡាយទឹក ត្រង់បន្លោះនៃខណ្ឌទាំងពីរ គឺខ្នង់វែង ៗ (ទាំងប៉ុន្មាន) ក្ដី សំពត់អនុវាតវែង ៗ (ទាំងប៉ុន្មាន) ក្ដី (ហៅថា កុសិ) ។ សង្ឃាដីត្រូវធ្វើពីរជាន់, ចីពរមួយជាន់, ស្បង់មួយជាន់ បើសង្ឃាដីបួនជាន់, ចីពរត្រូវធ្វើពីរជាន់, ស្បង់ពីរជាន់, ដោយពុទ្ធានុញ្ញាតថា អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ ឧតុទ្ធតានំ ទុស្សានំ ចតុគ្គុណំ សង្ឃាដឹ ទិគុណំ ឧត្តរាសង្គំ ទិគុណំ អន្តរវាសកំ បំសុកូលេ យាវទត្ថំ បាបណិកេ ឧស្សាហោ ករណីយោ អនុជានាមិ ភិក្ខវេ អគ្គឡំ តុន្នំ ឱវដ្ដិកំ កណ្ឌុសកំ ទឡ្ហីកម្មំ ។ (ប្រែថា) «ម្នាលភិក្ខុទាំងឡាយ កាល បើសំពត់នៅថ្មី ឬសំពត់ដែលគេទើបនឹងគក់ម្ដង តថាគត

អនុញ្ញាតឲ្យអ្នកទាំងឡាយ ធ្វើសង្ឃាដីពីរជាន់ ចីពរមួយជាន់ ស្បង់មួយជាន់, បើសំពត់នោះចាស់ តថាគតអនុញ្ញាតឲ្យធ្វើសង្ឃាដីបួនជាន់ ចីពរពីរជាន់ ស្បង់ពីរជាន់, អ្នកទាំងឡាយគួរស្វែងរកសំពត់បង្សុកូល សំពត់ដែលធ្លាក់ចុះចាកពានផ្សារតាមត្រូវការចុះ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអ្នកទាំងឡាយប៉ះផុល ដាក់ក្រវិលកណ្ដុំ និងដាក់កណ្ដុំ ធ្វើឲ្យមាំមួន” ។ ភ្នាតចីវរដែលថាធ្វើឲ្យត្រូវនឹងប្រមាណកុំឲ្យធំពេកតូចពេកនោះ គឺធ្វើកុំឲ្យធំប៉ុនចីវរព្រះសុគត ។ ភ្នាតចីពរសង្ឃាដីព្រះសុគត បណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាមដោយចំអាមព្រះសុគត, បើគិតជាហត្ថជាងឈើបណ្ដោយ ១៣ ហត្ថ ១ ចំអាម ទទឹង៩ហត្ថ ។ សេចក្ដីនេះពោលតាមពាក្យព្រះអដ្ឋកថាចារ្យដែលសំដែងទុកក្នុងគម្ពីរទុតិយសមន្តប្បាសាទិកាអដ្ឋកថា ថា តស្ស បមាណំ ឧក្កដ្ឋបរិច្ចេទេន សុគតចីវរតោ ឩនកំ វដ្ដតិ ។ លាមកបរិច្ចេទេន សង្ឃាដិយា ច ឧត្តរាសង្គស្ស ច ទីឃតោ មុដ្ឋិបញ្ចកំ តិរិយតោ

មុដ្ឋិតិកំ បមាណំ វដ្ដតិ ។ អនុវាតតោ ទីឃតោ មុដ្ឋិបញ្ចកោ តិរិយំ ទ្វិហត្ថោបិ វដ្ដតិ ។ វុត្តប្បមា-ណតោ បន អតិរេកញ្ច ឩនកញ្ច បរិក្ខារចោឡន្តិ អធិដ្ឋាតព្វំ ។ សេចក្ដីថា ចីវរត្រូវធ្វើឲ្យតូចជាងចីវរព្រះសុគត ទើបប្រើប្រាស់បាន ។ ខ្នាតចីពរសង្ឃាដីយ៉ាងតូចបំផុត ត្រូវធ្វើបណ្ដោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ១ គក់, ខ្នាតស្បង់បណ្ដោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ។ បើត្រៃចីវរដែលមានខ្នាតធំ ឬ តូចជាងខ្នាតដែលនិយាយមកនេះ អធិដ្ឋានមិនឡើងជាចីពរ ស្បង់ សង្ឃាដីឡើយ, ត្រូវអធិដ្ឋានបេញឈ្មោះជាបរិក្ខារចោឡៈ ទើបប្រើប្រាស់បាន ។

អំពីទំហំអនុវាតនិងខ្នងចីវរទាំងនេះ មិនឃើញមានបញ្ញត្តិឲ្យធ្វើទំហំប៉ុន្មាន ៗ ជាដាច់ខាតទេ, ប៉ុន្តែមានសេចក្ដីក្នុងអដ្ឋ-កថាចីវរក្ខន្ធកៈប្រាប់អំពីវិធីបែកសំពត់ថា បើសំពត់តិច ភិក្ខុបែកគ្នាមិនគ្រាន់ ត្រូវឲ្យកាត់ប្រៀកជាបម្រៀកៗយ៉ាងតូចបំផុតខាងទទឹង ៤ ធ្នាប់ ខាងបណ្ដោយលៃឲ្យល្មមធ្វើអនុវាតបាន ។

សេចក្ដីនេះ សឲ្យឃើញថា អនុវាតចីវរ យ៉ាងតូចបំផុតទំហំត្រឹម ៤ ធ្នាប់ក៏ប្រើបាន ។ ឧត្តរាសង្គៈនិងសង្ឃាដី បើធ្វើអនុវាតទំហំ ១៥ សង់ទីម៉ែត្រ ខ្នង់ទំហំ ៥ សង់ទីម៉ែត្រ, ស្បង់ធ្វើអនុ-វាតទំហំ ៨ ឬ ៩ សង់ទីម៉ែត្រ ខ្នង់ទំហំ ៤ ឬ ៥សង់ទីម៉ែត្រកន្ទះ នេះល្មម មិនធំពេកមិនតូចពេក ។ ដំណើរនេះ អ្នកស្ទាត់ក្នុងការលៃលក គួរលៃកាត់ឲ្យល្មមសមរម្យចុះ ។

## បិណ្ឌបាតប្បច្ច័យ

ភោជនាហារដែលត្រូវឆាន់បានតែក្នុងពេលគឺតាំងពីពេលព្រឹកទៅទល់នឹងថ្ងៃត្រង់ ហៅថា **បិណ្ឌបាតប្បច្ច័យ** ។ វត្ថុដែលជាភោជនាហារនោះ មានច្រើនយ៉ាងគឺ បាយ, នំ, ត្រី, សាច់, ផ្លែឈើ, មើមឈើជាដើម ។ វត្ថុណា ដែលលោករាប់បញ្ចូលថាជាភោជនាហារហើយ ទាយក មិនគប្បីប្រគេនដល់ភិក្ខុក្នុងវេលាវិកាល គឺតាំងពីវេលារសៀលទៅដល់យប់ឲ្យលោកទទួលផ្ទាល់ដៃឡើយ, បើប្រគេនដោយសំដីជាកប្បិយវោ-

ហារបាន គឺបវារណាឲ្យតែលោកដឹង ហើយប្រគល់វត្ថុនោះឲ្យដល់កប្បិយការកៈ គឺកូនសិស្សរបស់លោកឲ្យទទួលរៀបចំទុកដាក់សម្រាប់កិច្ចប្រគេនលោក, បំណែកលោកគ្រាន់តែទទួលដឹងដោយចិត្តប៉ុណ្ណោះក៏បានហើយ, បើប្រគេនដូច្នេះទើបលោកឆាន់ភោជននោះទៅថ្ងៃក្រោយទៀតបានឥតមានទោស ។ ភោជននេះកុំថាឡើយតែភិក្ខុទទួលផ្ទាល់ដៃក្នុងកាលខុស សូម្បីតែទទួលភោជនណាមួយក្នុងកាលត្រូវ ហើយទុកដាក់ដោយខ្លួនឯងឲ្យកន្លងរាត្រី ១ ឡើងទៅ, ភិក្ខុឆាន់ភោជននោះ ត្រូវអាបត្តិបាចិត្តិយៈ ត្រង់សន្និធិការកសិក្ខាបទដោយពិត ។ មួយទៀតភោជនាហារដែលត្រូវលេបចូលទៅក្នុងបំពង់កទាំងប៉ុន្មាន លុះតែគេប្រគេនដោយត្រឹមត្រូវទើបភិក្ខុឆាន់បាន វៀរលែងតែទឹកសុទ្ធ គឺទឹកដែលឥតលាយដោយវត្ថុអ្វីមួយ និងឈើស្ទន់ចេញមិនបាច់ប្រគេនទេ គ្រាន់តែយកទៅដាក់ក្បែរ ភិក្ខុប្រើប្រាស់ឆាន់បាន, ឯការប្រគេននោះត្រូវឲ្យប្រកបដោយអង្គ ៥ យ៉ាងទើបហៅថា ប្រគេន, ភិក្ខុទទួលឆាន់បានឥតមានទោស ។

## អង្គ ៥ យ៉ាងនោះគឺ

១– ថាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ វត្ថុដែលមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្តាលលើកម្នាក់ឯងរួច (តែមិនគប្បីសែងវត្ថុនោះប្រគេនជាមួយគ្នាទាំងពីរនាក់ឡើយ)[១] ។

២– ហត្ថបាសោ បញ្ញាយតិ ហត្ថបាសប្រាកដ គឺអ្នកប្រគេនឋិតនៅក្នុងហត្ថបាស ២ ហត្ថ ១ ចំអាម ។ ហត្ថបាសៈ ប្រែថា "អន្ទាក់ដៃ" ក្នុងទីនេះជាឈ្មោះឱកាសដែលត្រូវលាតដៃប្រគេន លាតដៃទទួល មិនលាតលូកឬឈោងដៃចូលឲ្យកើនលើសប្រមាណ ។ ឯពិធីដែលនឹងវៃហត្ថបាស ២ ហត្ថ ១ ចំអាមនោះ ដូច្នេះគឺ ចំណែកខាងទាយក (អ្នកប្រគេន) ត្រូវគិតហត្ថបាស ពីត្រឹមទីបំផុតខាងក្នុងអវយវៈចូលទៅ, ចំណែកខាងបដិគ្គាហកៈគឺភិក្ខុអ្នកទទួល ត្រូវគិតពីត្រឹម

---

១ ត្រង់នេះ ចូរមើលក្នុងសមន្តបាសាទិកា វិនយដ្ឋកថា និង កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ ទើបឃើញសេចក្តីទូលំទូលាយជាងនេះ ។

ទីបំផុតខាងក្រៅអរិយវៈចូលមក, ផ្សំគ្នាទៅ ឲ្យបានប្រវែង ២ ហត្ថ ១ ចំអាម, គឺបើទាយកឈើប្រគេនចំពីមុខ (ភិក្ខុ ក៏ឈរទទួលដែរ ដូចយ៉ាងទទួលភត្តដែលគេដាក់បាត្រ) ត្រូវគិតពីត្រឹមមេជើងទាយកចូលទៅទល់នឹងចុងបំផុតកែងជើងភិក្ខុ ឲ្យបានប្រវែង ២ ហត្ថ ១ ចំអាម, យ៉ាងនេះ ហៅថា ហត្ថបាស (មួយអន្ទាក់ដៃ) គឺល្មមលាតដៃប្រគេន លាតដៃទទួលបានដោយគោរព, បុរសក្តី ស្ត្រីក្តី អាចប្រគេន ឬដាក់បាត្របានដូចគ្នា ។ ទាយកនិងបដិគ្គាហកៈ អង្គុយដូចគ្នាក្តី ម្នាក់ឈរ ម្នាក់អង្គុយ ឬដេកក្តី ប្រគេនចំពីមុខក្តី ពីក្រោយឬពីខាងក្តី ក៏មានទំនងដូចន័យនេះដែរ, អ្នកប្រគេន ត្រូវគិតពីខាងក្នុងចូលទៅ អ្នកទទួល ត្រូវគិតពីខាងក្រៅចូលមក រួមប្រវែងហត្ថបាសទៅឲ្យបាន ២ ហត្ថ ១ ចំអាម, មិនមែនចាំបាច់វាស់ទេ គ្រាន់តែលៃស្មានមើលឲ្យឃើញល្មមបាន ២ ហត្ថ ១ ចំអាមប៉ុណ្ណោះ ឬឲ្យជិតជាងនេះបន្តិច ក៏ឥតទោស, កុំឲ្យតែជិតពេក បើស្ត្រីពុំក្រង ប្រគេនឬដាក់បាត្រពុំបាន ។

៣- អភិហារោ បញ្ញាយតិ អ្នកប្រគេនបន្ទន់ខ្លួនបង្អោនវត្ថុចូលមក គឺបង្អោនចូលមកសំដែងឲ្យឃើញថាជាអ្នកត្រូវការប្រគេនដោយគោរពពិតមែន ។

៤- ទេវេន វា មនុស្សេន វា តិរច្ឆានគតេន វា ទេតិ ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តី ប្រគេន គឺពិតជាមានគេប្រគេនមែន ។

៥- តំ បន ភិក្ខុ កាយេន វា កាយប្បដិពទ្ធេន វា បដិគ្គណ្ហាតិ ភិក្ខុទទួលវត្ថុនោះ ដោយកាយក្តី ដោយវត្ថុដែលជាប់ដោយកាយក្តី ។

ពាក្យថា ទទួលដោយកាយ នោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុលូកដៃទៅទទួលចាប់កាន់វត្ថុដែលគេប្រគេននោះដោយផ្ទាល់នឹងដៃ មិនមានយកភាជន៍ អ្វីនីមួយមានជើងពានជាដើមទៅទទួលយក ហៅថា ទទួលដោយកាយ ។

ពាក្យថា **ទទួលដោយវត្ថុដែលជាប់ដោយកាយ** នោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុកាន់សំពត់ ឬភាជន៍មានជើងពានជាដើម លូកទៅទទួលទស់យក ឬផ្ទេរយកវត្ថុដែលគេប្រគេននោះ មិនបានទទួលទស់យកផ្ទាល់នឹងដៃសុទ្ធ ហៅថា **ទទួលដោយវត្ថុដែលជាប់ដោយកាយ** ។

ន័យមួយទៀត ទេយ្យវត្ថុជា **ពីជគាម** ឬ **ភូតគាម** គឺវត្ថុដែលមានគ្រាប់, មើម, ដើម, ឫស, ទង ជាពូជល្មមដុះទៅទៀតបាន ដូចផ្លែម្ទេសទុំ, ត្របែកទុំ, មើមដំឡូង, ដើមអំពៅ, សណ្តែកបណ្តុះ, ទងដំឡូង, ទងកញ្ឆែតជាដើម, បើទាយកមានប្រាថ្នានឹងធ្វើទានដល់សមណៈក្នុងសាសនា គប្បីសុជ, ដុតពុះ, ចោះ, ចុច ឬ ស្រុស ធ្វើឲ្យសម្រេចជារបស់កប្បិយៈ ត្រូវតាមពុទ្ធានុញ្ញាត ដែលព្រះសម្ពុទ្ធ ទ្រង់អនុញ្ញាតសមណៈកប្ប ៥ ប្រការដល់ភិក្ខុទាំងឡាយ នោះទើបលោកទទួលឆាន់បាន មិនខុសនឹងបញ្ញត្តិកង **ភូតគាមសិក្ខាបទ** ។

## សមណកប្ប ៥ ប្រការនោះគឺ

១- អគ្គិបរិចិតំ វត្ថុដែលគេអុជដុតកំដៅភ្លើងឬស្រុស,

២- សត្ថបរិចិតំ វត្ថុដែលគេពុះចោះបិតដោយសស្ត្រា,

៣- នខបរិចិតំ វត្ថុដែលគេចុប ឬកេះដោយក្រចក,

៤- អពីជំ វត្ថុដែលគ្មានពូជដុះទៅទៀតបាន (ផ្លែខ្ចី),

៥- និព្វដពីជំ ផ្លែដែលមានពូជតែបន្ទេបយកគ្រាប់ចេញបាន ។

ការទទួលប្រគេនប្រកបដោយអង្គ ៥ និងអង្គនៃសមណកប្ប ៥ ប្រការនេះ គួរសាធុជនជាសប្បុរសទាំងឡាយ ខំយកចិត្តទុកដាក់សង្កេតមើលឲ្យបេះ ចូលចិត្តចាំស្ទាត់កុំខាន ព្រោះជាកិច្ច ឬជាផ្លូវដែលអស់លោកទាំងឡាយតែងធ្វើរឿយ ៗ ។

## សេនាសនប្បច្ច័យ

ទីសម្រាប់ដេក អង្គុយ មានកុដិសាលាជាដើម ហៅថា

**សេនាសនប្បច្ច័យ** ។ **សេនាសនប្បច្ច័យ** នេះ មានច្រើនប្រការណាស់ នឹងនាំយកតែបច្ច័យណាដែលមានដំណើរទាក់ទងច្រើន ដោយវិនយកិច្ច ហើយទាំងផនអ្នកមានសទ្ធាក៏តែងកសាងរឿយ ៗ មកអធិប្បាយ ។

ទីសេនាសនៈគឺ កុដិ សាលា វិហារ បើទាយកនឹងគិតសាងត្រង់ទីណាមួយបំពោះភិក្ខុសង្ឃ លុះតែឲ្យសង្ឃសំដែងទីឲ្យជាមុន គឺឲ្យសង្ឃពិនិត្យទីកន្លែងដែលបម្រុងនឹងកសាងនោះឲ្យឃើញថាជាទីបរិសុទ្ធ ផុតចាកសេចក្ដីរង្កៀស ឥតមានទាក់ទាមទៅលើទីដីអ្នកណាមួយទេ ទាំងសង្ឃអនុញ្ញាត យល់ព្រមឲ្យធ្វើ ទើបទាយកនោះអាចធ្វើបាន ទាំងភិក្ខុសង្ឃក៏ទទួលយកនៅអាស្រ័យបាន ។

បំណែកគ្រែនិងតាំង ដែលត្រូវធ្វើឲ្យមានជើងនោះ យ៉ាងខ្ពស់បំផុតត្រឹម ៨ ធ្នាប់ព្រះសុគតគិតពីត្រឹមមេគ្រែខាងក្រោមចុះមក គឺកំពស់ ២៤ ធ្នាប់ជាងឈើ ត្រូវជា ៤០ សង់ទីម៉ែត្រដែលនិយមប្រើសព្វថ្ងៃនេះ ហើយកុំញាត់ដោយគរឬសំឡី ទើបភិក្ខុទទួលប្រើប្រាស់បាន មិនកន្លងបញ្ញត្តិត្រង់ ឆទនកសិក្ខាបទ

និង ត្រូវលោនទូលិក្ខាបទ ។ គ្រឿងកម្រាល មិនត្រូវធ្វើញាត់ដោយគរឬសំឡីឡើយ គប្បីញាត់ដោយវត្ថុណាមួយដ៏សមគួរតាមពុទ្ធានុញ្ញាត ដែលទ្រង់អនុញ្ញាតពួក ៥ យ៉ាងឲ្យភិក្ខុប្រើប្រាស់នោះ ទើបភិក្ខុទទួលប្រើប្រាស់បាន ឥតមានទោស ។

ពួក ៥ យ៉ាងនោះគឺ

១- ឧណ្ណភិសិ ពូកញាត់រោមចៀម,

២- ចោឡភិសិ ពូកញាត់កំណាត់សំពត់,

៣- វាកភិសិ ពូកញាត់សំបកឈើ,

៤- តិណភិសិ ពូកញាត់ស្មៅ,

៥- បណ្ណភិសិ ពូកញាត់ស្លឹកឈើ ។

**គិលានភេសជ្ជប្បច្ច័យ**

ថ្នាំជាបច្ច័យសម្រាប់រក្សាជម្ងឺ ហៅថា **គិលានភេសជ្ជប្បច្ច័យ** ។ ថ្នាំត្រាំដោយទឹកមូត្រគោនិងភេសជ្ជៈ ៥ យ៉ាងគឺ

ទឹកដោះរាវ ១ ទឹកដោះខាប់ ១ ប្រេង ១ ទឹកឃ្មុំ ១ ទឹកអំពៅ ១ ជាដើម, ភេសជ្ជៈទាំងប៉ុន្មាននេះ លុះតែគេប្រគេនត្រឹមត្រូវតាមអង្គនៃការប្រគេន ដូចបិណ្ឌបាតប្បច្ច័យដែរ ទើបភិក្ខុទទួលឆាន់បាន ឥតមានទោស ។

បណ្ដាបច្ច័យទាំង ៤ យ៉ាងដូចពណ៌នាមកហើយខាងលើនោះ ចីវរប្បច្ច័យ និង សេនាសនប្បច្ច័យ ទាយកប្រគេនដោយវាចា គឺគ្រាន់តែសូត្របាលីវេរ ឬគេនិយាយប្រគេនជាសម្រាយក៏បានឈ្មោះថាប្រគេនពិត, ភិក្ខុទទួលប្រើប្រាស់បាន ឥតមានទោស ព្រោះជាបច្ច័យមិនបានលេបចូលទៅក្នុងបំពង់ក ។

ឯ បិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ទោះទាយកបាននាំយកមកតាំកល់ទុក ក្នុងទីចំពោះមុខភិក្ខុសង្ឃ ជាប់បាត្តបាស រួចសូត្រវេរជាបាលី ឬសម្រាយ សព្វគ្រប់ហើយក៏ត្រូវតែទាយកលើកបច្ច័យនោះប្រគេន ឲ្យត្រូវតាមអង្គទាំង ៥ ប្រការនោះទៀត ទើបហៅថា ប្រគេន, ភិក្ខុក៏ទទួលឆាន់បានឥតមានទោស ។

ន័យមួយទៀត បិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ទាំងពីរនេះ បែកទៅតាមកាលមាន ៤ យ៉ាងគឺ

១_ *យាវកាលិក* បច្ច័យដែលភិក្ខុគួរឆាន់បានពីត្រឹមពេលព្រឹកទៅទល់នឹងថ្ងៃត្រង់,

២_ *យាមកាលិក* បច្ច័យដែលភិក្ខុគួរទទួលទុកដាក់ឆាន់បានពីត្រឹមពេលព្រឹកទៅទល់នឹងអរុណរះ (១ យប់ ១ថ្ងៃ),

៣- *សត្តាហកាលិក* បច្ច័យដែលភិក្ខុទទួលទុកដាក់ឆាន់បាន យ៉ាងយូរត្រឹម ៧ ថ្ងៃ,

៤_ *យាវជីវិក* បច្ច័យដែលភិក្ខុទទួលទុកដាក់ឆាន់បានដរាបទល់នឹងអស់ (មិនមានកំណត់ថ្ងៃ) ។

## អធិប្បាយ

១- វត្ថុដែលរាប់ថាជាភោជនាហារទាំងប៉ុន្មាន មានបាយ, នំ, ត្រី, សាច់ និងដើមឈើ ផ្លែឈើ មានដើមដំឡូង ផ្លែបែក

ជាដើម ហៅថាយាមកាលិក, ភិក្ខុត្រូវទទួលទុកដាក់ឆាន់បាន ពីត្រឹមពេលព្រឹកដល់ថ្ងៃត្រង់, ទុកឲ្យកន្លងរាត្រី ឆាន់មិនបាន,

២- ទឹក ៨ ប្រការដែលគេធ្វើឲ្យសម្រេចដោយផ្លែឈើជាដើម គឺ *អម្ពបានំ* ទឹកផ្លែស្វាយ ១ *ជម្ពូបានំ* ទឹកផ្លែព្រីង ១ *ចោចបានំ* ទឹកផ្លែចេកមានគ្រាប់ ១ *មោចបានំ* ទឹកផ្លែចេកឥតគ្រាប់ ១ *មធុកបានំ* ទឹកផ្លែស្រគំ ១ *មុទ្ទិកបានំ* ទឹកផ្លែចាន់ *សាលុកបានំ* ទឹកមើមនៃផលជាតិមានព្រលឹតក្រហមឬលំបង់ជាដើម ១ *ផារុសកបានំ* ទឹកផ្លែមាក់ប្រាង ១ ។

មានទឹក ៨ យ៉ាងទៀតគឺ *កោសម្ពបានំ* ទឹកផ្លែសង្កែ ១ *កោលបានំ* ទឹកផ្លែពុទ្រាតូច ១ *ពទរបានំ* ទឹកផ្លែពុទ្រាធំ *ឋគ្គបានំ* ទឹកធ្វើដោយទឹកដោះរាវ ឬ

ទឹកដោះថ្លា ១ *តេលបានំ* ទឹកធ្វើដោយប្រេងមានប្រេងល្ង ជាដើម ១ *បយោបានំ* ទឹកធ្វើដោយទឹកដោះស្រស់ ១ *យាគុបានំ* ទឹកធ្វើដោយបបរ ១ *រសបានំ* ទឹកធ្វើដោយរសជាតិនៃវត្ថុមានបន្លែជាដើម ១ ។ **ឱភបាន** ទាំងនេះ ជាភេសជ្ជៈ **យាមកាលិក**, ភិក្ខុឆាន់ក្នុងវេលាវិកាលបាន តែទទួលទុកដាក់ឆាន់បានត្រឹម ១ថ្ងៃ ១ យប់ប៉ុណ្ណោះ យ៉ាងយូរ, បើទុកឲ្យហួសពីកាលកំណត់នេះ ហើយភិក្ខុយកមកឆាន់, ត្រូវអាបត្តិទុក្កដ ។

៣- ភេសជ្ជៈ ៥ យ៉ាង (មានទឹកដោះរាវជាដើម) និងថ្នាំដែលផ្សំដោយខ្លាញ់ គឺខ្លាញ់ខ្លាឃ្មុំ ខ្លាញ់ត្រី ខ្លាញ់ក្រពើ ខ្លាញ់ជ្រូក ខ្លាញ់លា ជាដើម, ភេសជ្ជៈនេះហៅថា **សត្តាហកាលិក**, ភិក្ខុត្រូវទទួលទុកដាក់ឆាន់បាន យ៉ាងយូរបំផុត

ត្រឹម៧ថ្ងៃ, បើទុកឲ្យហួសពីកាលនេះ ហើយភិក្ខុយកមកឆាន់, ត្រូវអាបត្តិទុក្កដ ។

៤- ភេសជ្ជៈដែលត្រាំដោយទឹកមូត្រគោ និងថ្នាំដែលផ្សំដោយមើមឬឫស គឺមើមរមៀត, មើមខ្ញី, មើមលំពាន់, មើមប្រស់, មើមអាប់ផ្តស, មើមរំដេង, មើមស្មៅក្រវាញជ្រូក, ឫសស្បូវភ្លាំងជាដើម, ភេសជ្ជៈនេះហៅថា **យាវជីវិក**, ភិក្ខុទទួលទុកដាក់ឆាន់បាន ដរាបទល់នឹងភេសជ្ជៈនោះអស់ មិនមានកំណត់កាលឡើយ ។

ការធ្វើ **ទាន** ដូចបានរៀបរៀងទុកមកហើយខាងដើមនោះ ទោះទាយកធ្វើនឹងសមណៈក្នុងព្រះពុទ្ធសាសនាជាបាដិ-បុគ្គលិកទាន ឬ ជាសង្ឃគតាទក្ខិណាទានជាដើមក្តី ធ្វើនឹងសមយាចក ជាអ្នកក្រីក្រលំបាក អនាថាឥតមានទីពឹង តែជាអ្នកទ្រទ្រង់សីល ៥ ជាដើមក្តី ឥតទ្រទ្រង់សីលធម៌គ្តី ឬក៏ធ្វើនឹងសត្វតិរច្ឆានក្តី ដែលនឹងកំណត់ឲ្យដឹងថា ជាទានមាន

ផលតិចច្រើន ឬខ្ពស់ទាបយ៉ាងណាបាននោះ សប្បុរសគប្បីសង្កេតមើលសេចក្ដី ក្នុង **ទានលក្ខណកថា** ដែលបានអធិប្បាយពន្យល់អំពីវិធីធ្វើទានរួចមកហើយនោះ ឲ្យបានចូលចិត្តដាក់ណាក់ រួចចូរនិងប្ដូយកំណាត់យកទុកក្នុងចិត្តចំពោះខ្លួនចុះ ។

ឯអានិសង្សនៃទាននេះ នឹងមានសំដែងក្នុង **ទានានិសំសកថា** ជាសេចក្ដីសង្ខេបខ្លីចមានតទៅខាងក្រោយនេះ ។

**ទានលក្ខណកថា ចប់ដោយសង្ខេប ។**

ទាន មានដំណើរផ្សេងៗ ទាក់ទងដោយវត្ថុខ្លះ ដោយចេតនាខ្លះ ដោយបុគ្គលអ្នកឲ្យខ្លះ បុគ្គលអ្នកទទួលខ្លះ តាមឈ្មោះផ្សេងៗ ពីគ្នា តែបើពោលតាមភូមិនៃបុគ្គលនិងវត្ថុ មាន ៣ យ៉ាងគឺ បុគ្គលណា បរិភោគវត្ថុថោកទាបដោយខ្លួនឯង លុះត្រូវការធ្វើទាន ក៏ចាត់ចែងឲ្យវត្ថុដ៏ថ្លៃថ្លាដល់បុគ្គលដទៃ, បុគ្គលនោះឈ្មោះថា **ទានបតិ** ឬ **ទានស្សាមី** ប្រែថា អ្នកមានទានជាម្ចាស់ គឺថា លើកទានឲ្យជាម្ចាស់របស់ខ្លួន ១ ; បុគ្គលណាបរិភោគវត្ថុបែបណា ដោយខ្លួនឯង លុះត្រូវការឲ្យទាន ដល់បុគ្គលដទៃ ក៏ឲ្យវត្ថុបែបនោះដែរ, បុគ្គលនោះឈ្មោះថា **ទានសហាយៈ** ប្រែថា អ្នកមានទានជាសំឡាញ់ ១ ; បុគ្គលណាបរិភោគវត្ថុថ្លៃថ្លាដោយខ្លួនឯង លុះវេលាឲ្យទាន ក៏ត្រឡប់ជាយកវត្ថុថោកទាបទៅឲ្យទានដល់បុគ្គលដទៃវិញ, បុគ្គលនោះឈ្មោះថា **ទានទាសៈ** ប្រែថា អ្នកមានទានជាខ្ញុំ ១ ៗ

ការបរិច្ចាគទាន តាមភូមិនៃបុគ្គលនិងវត្ថុ ដូចបានពោលមកនេះ **រមែងបានអានិសង្ស** តាមថ្នាក់ យ៉ាងខ្ពង់ខ្ពស់,

កណ្ដាល, ហៅកទាប តាមលំដាប់នៃទាននោះ ៗ ។ ទាននេះ ចាត់ជាកល្យាណវត្ថុមួយដ៏ប្រសើរ រមែងមាននៅប្រចាំលោក, ជាករណីយកិច្ចរបស់សប្បុរសដោយពិត តែជាទំនាស់របស់មនុស្សកំណាញ់, ទាននេះ រាប់ថាជាបវេណិធម៌ របស់បុព្វបុរស ឬចាត់ជាបុញ្ញនិធិ ជាទីពឹងពំនាក់របស់សត្វលោក ។ ទាន រមែងសម្រេចប្រយោជន៍ឃើញជាក់ច្បាស់ ទាំងផ្លូវលោក និងផ្លូវធម៌ដោយពិត ។

បុគ្គលអ្នកឲ្យទាន ឈ្មោះថា បានឲ្យអាយុ, ឲ្យពណ៌សម្បុរ, ឲ្យសេចក្ដីសុខ, ឲ្យកម្លាំង, ឲ្យសេចក្ដីអង់អាច ដល់បុគ្គលដទៃ ។ ការឲ្យទាននេះ ឈ្មោះថា ជាអ្នកចងមិត្តឬប្រមូលកម្លាំងទុកដោយប្រពៃ ព្រោះថា មនុស្សក្នុងលោករមែងមានកិច្ចរវល់ជាធម្មតា កាលបើកិច្ចការដែលត្រូវធ្វើកើតឡើង បុគ្គលអ្នកគិតមិត្តសំឡាញ់ រមែងបានសេចក្ដីលំបាកដោយកិច្ចការនោះ ៗ ផ្ទាល់ខ្លួនឯង, កាលបើមានមិត្តសំឡាញ់ត្រឹមណា ឈ្មោះថាមានកម្លាំងច្រើនត្រឹមណោះ ។ ទាននេះ ចាត់ជាមិត្តសំឡាញ់ ឬជាកម្លាំងដ៏ប្រសើរ, ជាបច្ច័យជួយជូនដំណើរឲ្យ

បានសេចក្ដីសុខ សេចក្ដីចម្រើនដ៏ធំទូលាយ តាំងអំពីលោកនេះ រហូតដល់លោកខាងមុខ ។ រាងកាយទាំងមូល ត្រូវមានអវយវៈគឺដៃជើងជាមិត្តសំឡាញ់ ឬជាកម្លាំង សម្រាប់ទទួលធុរៈបានដោយស្រួល យ៉ាងណាមិញ, បុគ្គលអ្នកមានសទ្ធា ត្រេកអរក្នុងការបរិច្ចាគទាន ក៏រមែងបានទាននោះឯង ជាមិត្ត ជាកម្លាំងរបស់ខ្លួន យ៉ាងនោះដែរ ។ បុគ្គលមិនមានសទ្ធា ជាអ្នកប្រកបដោយសេចក្ដីកំណាញ់ ឈ្មោះថា បុគ្គលគ្មានមិត្តសំឡាញ់ ឬគ្មានកម្លាំង ដូចគ្នានឹងរាងកាយដែលកំបុតអវយវៈគឺដៃជើង ។ ទាននេះ ប្រាកដជាមានគុណានិសង្សច្រើនយ៉ាង តែបើពោលដោយរួបរួមចំពោះអានិសង្សនៃទាននេះ មាន ៥ យ៉ាងគឺ

១- *បិយោ ហោតិ មនាបោ* អ្នកឲ្យទានរមែងជាទីស្រឡាញ់ ពេញចិត្តនៃអ្នកផងច្រើនគ្នា ដែលនៅជិតខាង ឬនៅក្នុងទីឆ្ងាយ

២- *សប្បុរិសា ភជន្តិ* ពួកសប្បុរស រមែងរាប់រក សង្គ្រោះនូវបុគ្គលដែលមានសទ្ធាធ្វើទាន ដោយការស្និទ្ធ

រកប្រយោជន៍ និងប្រាថ្នាចង់ឲ្យបុគ្គលអ្នកឲ្យទាននោះ បាន
សេចក្ដីសុខចម្រើនគ្រប់កាល

*៣- កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ*
កិត្តិសព្ទដ៏ពិរោះ រមែងខ្ចរខ្ចាយ សុះសាយទៅក្នុងទិសទាំងពួង
ទាំងមនុស្សនិងទេវតា ក៏រមែងឲ្យសព្ទសាធុការ,

*៤- វិសារទោ ឧបសង្កមតិ* អ្នកឲ្យទាន ទោះ
ចូលទៅកាន់បំណោមបរិស័ទណាមួយ រមែងមានសេចក្ដីក្លៀវ
ក្លា អង់អាច មិនក្រអឹមក្រអៀម,

*៥- សុគតឹ សគ្គំ លោកំ ឧបបជ្ជតំ* អ្នកឲ្យ
ទាន លុះបែកធ្លាយរាងកាយឃ្លាតចាកលោកនេះ ក៏ទៅកើត
ឯសុគតិសួគ៌ទេវលោក លុះច្យុតចាកទេវលោក ដោយអំណាច
ឧស្សន្នកុសលផាប់មក ក៏បានកើតមកក្នុងមនុស្សលោកនេះ
ទៀត រមែងកើតក្នុងត្រកូលខ្ពស់ ដែលសម្បូណ៌ដោយភោគ
សម្បត្តិ ។

អានិសង្ស ទាំង ៥ យ៉ាងដូចពោលមកនេះ បែកចេញជាពីរផ្នែកគឺ **អានិសង្ស ៤** ខាងដើម ជា **សន្ទិដ្ឋិកផល** គឺផលដែលគួរឃើញជាក់ច្បាស់ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ, អានិសង្ស មួយខាងចុង ជា **សម្បរាយិកផល** គឺផលដែលត្រូវបានជួបប្រទះឃើញច្បាស់ក្នុងបរលោក ។ ពណ៌នាមកនេះ ជា **អានិសង្ស** នៃ **អាមិសទាន** ។

លំដាប់ពីនេះ សូមសំដែងអំពី អានិសង្ស នៃ **ធម្មទាន** ដោយសង្ខេបតទៅទៀត ។

ការសំដែងធម៌ជាសាធារណៈដល់បុគ្គលដទៃក្តី ប្រៀនប្រដៅប្រាប់អំពីគុណទោសខុសត្រូវក្នុងផ្លូវលោកផ្លូវធម៌ ចំពោះមនុស្សម្នាក់ ៗ ក្តី បង្ហាត់បង្រៀនធម៌អាថ៌ចំពោះពួកគណៈសាធារណៈក្តី ហៅថា **ធម្មទាន** ទាំងអស់ ។ ធម្មកថិក (លោកអ្នកសំដែងធម៌) សំដែងធម៌អាថ៌ ឈ្មោះថា ប្រគល់នូវចំណេះវិជ្ជាប្រាជ្ញាស្មារតីដ៏ធំទូលាយ ដល់បុគ្គលដទៃ, ដូចយ៉ាងបុគ្គលដែលបានទទួលអំណោយសេចក្តីសុខ ដោយភោគសម្បទ ឬ

ដោយឋានន្តរ គឺតំណែងយសស័ក្តិណាមួយ សុទ្ធតែបានមក អំពីការរៀនសូត្រស្តាប់ទាំងអស់ ឬថា មានការស្តាប់នេះឯងជាមូលហេតុ ។ ការសិក្សា ការត្រងត្រាប់ស្តាប់យកឧបាយ នេះរាប់ថាជាមេគំនិត ឬជាដើមពូជ នៃប្រយោជន៍ សេចក្តីល្អគ្រប់យ៉ាង, បុគ្គលដែលបានសម្រេចមគ្គផលនិព្វាន ជាគុណវិសេសដ៏ខ្ពស់បំផុត ព្រោះអាស្រ័យការស្តាប់នេះឯងជាបច្ច័យ ។

ចំណែកខាងបុគ្គលអ្នកប្រៀនប្រដៅធម៌ ឈ្មោះថា ឲ្យទានព្រះនិព្វាន, សមដូចពុទ្ធភាសិតថា អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ បុគ្គលណា ប្រៀនប្រដៅធម៌, បុគ្គលនោះ ឈ្មោះថា ឲ្យព្រះនិព្វាន (ដល់អ្នកដទៃ) ។ សព្វទានំ ធម្មទានំ ជិនាតិ ធម្មទាន រមែងឈ្នះទានទាំងពួង ។

**ធម្មទាន** ជាទានមានផលដ៏ខ្ពង់ខ្ពស់ ឈ្នះអាមិសទានទាំងអស់ ដោយហេតុថា ជាប្រធាន ឬថា ជាជីវិតនៃអាមិសទាន ។

**ធម្មទាន** ជាអាយុនៃពុទ្ធសាសនា អាចធ្វើព្រះពុទ្ធសាសនាឲ្យមានពន្លឺរស្មីរុងរឿងដរាបមក ។ ការសំដែងធម៌ ដល់អ្នក

ដទៃ កាលបើអ្នកស្តាប់ ទទួលស្តាប់ដោយគោរព រមែង បានអានិសង្សដ៏ប្រសើរ, ទាំងធម្មកថិកលោកអ្នកសំដែងធម៌ ក៏ បានទទួលអានិសង្សដ៏ថ្លៃថ្លាច្រើនយ៉ាងមកវិញ; បើពោលដោយ រួបរួម **អានិសង្ស** នៃ **ធម្មទាន** នេះ មាន ៥ ប្រការគឺ

១_ *អត្ថប្បដិសំវេទី ធម្មប្បដិសំវេទី* លោក អ្នកសំដែង កាលបើសំដែងដោយផ្ចិតផ្ចង់តាមអង្គនៃធម្មកថិក បំពោះព្រះសទ្ធម្ម នឹងរឹងរឹតតែជាអ្នកយល់ច្បាស់ ជ្រះថ្លាយ ក្នុង អត្ថក្នុងធម៌ត្រៃលែងឡើងទៅទៀត,

២– *បាមោជ្ជំ* សេចក្តីរីករាយក្នុងអត្ថក្នុងធម៌ រមែង កើតឡើង គឺធម្មទេសនានោះក៏ពីរោះជាប់ចិត្តខ្លួនឯងនិងបុគ្គល អ្នកស្តាប់ តាមលំដាប់នៃធម៌ដែលលើកឡើងសំដែង,

៣– *បីតិ* សេចក្តីត្រេកអរមានកម្លាំងផ្ទែតចិត្តក្នុងអត្ថ ក្នុងធម៌នោះ ៗ ក៏កើតឡើង,

៤- *បស្សទ្ធិ* រូបកាយនិងនាមកាយរបស់លោកអ្នកសំដែងនិងអ្នកស្តាប់ ក៏ស្ងប់រម្ងាប់បាតអកុសលធម៌ផ្សេង ៗ ដរាបដល់ចិត្តសង្វេគ តក់ស្លុតក្នុងសង្ខារទាំងឡាយ,

៥- *សមាធិ* ចិត្តរបស់លោកដែលកំពុងសំដែងធម៌ក៏តាំងមាំក្នុងការស្ងប់ស្ងាត់បាតនីវរណៈ ។ **អានិសង្ស** ទាំង៥ យ៉ាងនេះជា **សន្ទិដ្ឋិកផល** គឺផលដែលឃើញច្បាស់ក្នុងបច្ចុប្បន្ននេះក៏មាន ជា **សម្បរាយិកផល** គឺផលដែលត្រូវមានជាប់តទៅក្នុងបរលោកក៏មាន ។

ពណ៌នាមកក្នុងទានានិសំសកថា ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

របស់ក្រុមជំនុំប្រែព្រះត្រៃបិដក ដែលស្រង់ផ្ទួចកុង្វៀយ៍សេនាបតី ដោយសេចក្ដីពិនិត្យត្រឹមត្រូវតាមគម្ពីរវិន័យបិដក ។ ខ្ញុំស្រង់យកមករៀបរៀងក្នុងប៉ែកខាងចុងសៀវភៅនេះ ដើម្បីឲ្យអ្នកសិក្សាងាយយល់ ។

## អំពីកន្ទេរចីវរ

ចីវរបញ្ចខណ្ឌ (ចីវរ ៥ ផ្ទាំង) មានកន្ទេរតែ ១០ កត់ គឺ កន្ទេរធំ ៥ ហៅតាមព្រះពុទ្ធដីកាថា មណ្ឌលៈ ហៅតាមអដ្ឋកថាថា មហាមណ្ឌលៈ កន្ទេរតូច ៥ ហៅតាមព្រះពុទ្ធដីកាថា អឌ្ឍមណ្ឌលៈ ហៅតាមអដ្ឋកថាថា ខុទ្ទកមណ្ឌលៈ; រួមជាកន្ទេរ ១០ កត់ ។

ក្នុងខណ្ឌគឺផ្ទាំងមួយ ៗ ត្រូវចែងជា ៣ ភាគ, យកពីរភាគធ្វើជាកន្ទេរធំ (ព្រោះហេតុនោះបានជាហៅ មហាមណ្ឌលៈ

ប្រែថា "កន្សែងធំ)", យកមួយភាគធ្វើជាកន្សែងតូច (ព្រោះហេតុនោះ បានជាហៅ អឌ្ឍមណ្ឌលៈ ប្រែថា "កន្សែងកន្លះភាគ ឬកន្សែងពាក់កណ្តាលពីកន្សែងធំ" ឬហៅ ខុទ្ទកមណ្ឌលៈ ប្រែថា "កន្សែងតូច" ក៏បាន) ។

ក្នុងគម្ពីរយោជនាមហាវគ្គ ចីវរក្ខន្ធកៈ មានសេចក្តីប្រាប់ដោយដាច់ខាតថា បញ្ច មហាមណ្ឌលំ បញ្ច ខុទ្ទកមណ្ឌលំ កន្សែងធំ ៥ កន្សែងតូច ៥ (រួមជា ១០ គត់) ។

**ចីវរបញ្ចខណ្ឌ** ត្រូវធ្វើឲ្យមានកន្សែងត្រឹមតែ ១០ គត់ប៉ុណ្ណោះ ទើបត្រូវតាមគម្ពីរព្រះពុទ្ធសាសនា, ដូចគម្រូដែលគូរភ្ជាប់មកជាមួយនេះ ។

បើទុកជាចីវរដែលមានផ្ទាំងច្រើនលើសពី ៥ ទៅក៏ដោយ, ក្នុងផ្ទាំងមួយ ៗ ត្រូវធ្វើឲ្យមានកន្សែងត្រឹមតែពីរ ៗ គឺកន្សែងធំ១ កន្សែងតូច ១ ដូចគ្នានឹងចីវរបញ្ចខណ្ឌដែរ ។ **ចីវរសត្តខណ្ឌ** (ចីវរ ៧ ផ្ទាំង) មានកន្សែង ១៤ គឺកន្សែងធំ ៧ តូច ៧ ។ **ចីវរនវខណ្ឌ** (ចីវរ ៩ ផ្ទាំង) មានកន្សែង ១៨ គឺកន្សែងធំ ៩

តួប ៩ ។ ចីវរឯការឧសខណ្ឌ (ប៊ីវរ ១១ ផ្ទាំង) មានកន្សែង ២២ គឺកន្សែងធំ ១១ តួប ១១ ។ របៀបចីវរដែលត្រឹមត្រូវតាមពុទ្ធានុញ្ញាតមានតែ ៤ យ៉ាងប៉ុណ្ណោះ ។

## អំពីដេរចីវរ

ចីវរនិងស្បង់ទាំង ២ យ៉ាងនេះ ត្រូវដេរតែ ១ ជាន់គ្រប់អន្ទេ, លើកលែងតែត្រង់អនុវាតជុំវិញ និងត្រង់កន្លែងឈ្មោះគីវេយ្យកៈ និង ជង្ឃេយ្យកៈ ចេញ ដែលត្រូវឲ្យដេរប៉ះសាច់សំពត់ថែមជា ២ ជាន់ ឬ ៣ ជាន់ក៏បាន ដើម្បីឲ្យមាំជាប់បានយូរ ដ្បិតសាច់សំពត់ត្រង់កន្លែង ៣ អន្ទើនេះធាប់រេចណាស់ ។ មានបាលីបង្គាប់ឲ្យដេរថា ឯកច្ចិយំ ឧត្តរាសង្គំ "ចីវរឲ្យដេរតែ ១ ជាន់", ឯកច្ចិយំ អន្តរវាសកំ "ស្បង់ឲ្យដេរតែ ១ ជាន់" ។ ដោយហេតុនេះបានជាខ្លង់ចីពរនិងខ្លង់ស្បង់ត្រូវដេរថ្មេរមូល បញ្ចៀសកុំឲ្យទៅជា ២ ជាន់, បើដេរថ្មេរប្រក់នឹងទៅជា ២ ជាន់ខ្លះ ត្រង់ខ្នង់ដែលប្រក់, ទៅជា ១ ជាន់ខ្លះ ត្រង់

សាច់ស៊ំពត់លាតក្រៅពីរខ្វង់, ខុសអំពីពុទ្ធានុញ្ញាត ដែលថា ឯកង្គុលំ "ឲ្យដេរតែ ១ ជាន់" ។

មួយយ៉ាងទៀត មានពុទ្ធានុញ្ញាតថា ទិគុណំ សង្ឃាដិ "សង្ឃាដី ២ ជាន់" គឺ ២ ជាន់គ្រប់អន្លើ, លើកលែងតែត្រង់ **អនុវាត** និង **គីវេយ្យកៈ** និង **ជង្ឃេយ្យកៈ** ទាំង ៣ អន្លើនេះចេញ ដែលមានបង្គាប់ឲ្យដេរប៉ះថែមជា ២ ជាន់ ជាន់ក៏បាន លើសពីនេះទៅក៏បាន ដើម្បីឲ្យមាំជាងឯទៀត ។ ចីពរ ស្បង់ សង្ឃាដី ទាំង ៣ យ៉ាងនេះ បានជាមានឈ្មោះហៅខុសគ្នា ព្រោះមានបែបផ្សេង ៗ ពីគ្នា, បើប្រសិនជាដូច ៗ គ្នា តើចាំបាច់ឲ្យឈ្មោះផ្សេងគ្នាធ្វើអ្វី? ដូចជាសម្លៀកបំពាក់របស់គ្រហស្ថ ដែលមានឈ្មោះហៅ ផ្សេង ៗ ពីគ្នា ដូច្នោះដែរ ។

## សម្រេចសេចក្ដី

ក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ បានព្រមព្រៀងសម្រេចសេចក្ដីថា **ចីពរបញ្ចខណ្ឌ**

មានកន្សែងត្រឹម ១០ គត់ គឺកន្សែងធំ ៥ កន្សែងតូច ៥ ។ ខ្ទង់ចីពរនិងខ្ទង់ស្បង់ត្រូវដេរស្ទរម្ងូល គឺដេរទុកសាប់សំពត់ត្រង់កណ្ដាលខ្ទង់តែ ១ ជាន់ ៗ គ្រប់អន្លើ, កុំដេរខ្ទង់ប្រក់ជា ២ ជាន់ឡើយ ៗ ធ្វើចីវរបែបនេះ ទើបត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។

# ចីវរបញ្ចខណ្ឌចុះឈ្មោះអង្គទាំង ៩



*អង្គចីវរទាំង ៩ យ៉ាង (ស្រង់រៀបរៀងតាមលំដាប់)*

១- *កុសិ* ប្រែថា "បម្រៀកសំពត់វែង" នៅត្រង់អនុភាគវែង ៗ ជុំវិញនិងត្រង់ទ្រង់វែង ៗ ; ២- *អឌ្ឍកុសិ* ប្រែថា "បម្រៀកសំពត់កន្លះភាគពីកុសិ គឺបម្រៀកសំពត់ខ្លី ៗ" នៅត្រង់ទ្រង់ខ្លី ៗ ; ៣- *មណ្ឌលៈ* ប្រែថា "កន្លែងធំ" នៅត្រង់ផ្ទាំងធំ ៗ (បើចីវរបញ្ចខណ្ឌ កន្លែងធំនេះ មាន ៥ ផ្ទាំង); ៤- *អឌ្ឍមណ្ឌលៈ* ប្រែថា "កន្លែងកន្លះភាគពីកន្លែងធំ គឺកន្លែងតូច" នៅត្រង់ផ្ទាំងតូច ៗ (បើចីវរបញ្ចខណ្ឌ កន្លែងតូចនេះមាន ៥ ផ្ទាំង); ៥- *វិវដ្ដៈ* ប្រែថា "ផ្ទាំងសំពត់បើកពេញ (កាលណាឃ្លុំ ឃើញច្បាស់ពីត្រង់ខាងលើខ្នង)", អង្គនេះ នៅត្រង់ផ្ទាំងធំកណ្ដាល; ៦- *អនុវិវដ្ដៈ* ប្រែថា "ផ្ទាំងសំពត់បើកបន្ទាប់ (កាលណាឃ្លុំ ឃើញតែ ១ ចំហៀង", អង្គ

នេះ នៅត្រង់ផ្ទាំង ២ អឌ្ឍវិវដ្តៈ (មួយម្ខាង;) ៧–គីវេយ្យកៈ ប្រែថា "សំពត់ត្រូវរុំព័ទ្ធក (កាលណាឃ្លុំត្រូវរុំព័ទ្ធត្រង់ក)", អង្គនេះ នៅត្រង់ផ្ទាំងវិវដ្តៈបែកខាងលើ; ៨– ជង្ឃេយ្យកៈ ប្រែថា "សំពត់ត្រូវគ្របលើស្មង (កាលណាឃ្លុំ ត្រូវនៅត្រង់ខាងលើស្មង)", អង្គនេះ នៅត្រង់ផ្ទាំងអនុវិវដ្តៈទាំង ២ បែកខាងក្រោម; ៩–ពាហន្តៈ ប្រែថា "សំពត់ត្រូវគ្របកំភួន-ដៃ (កាលណាឃ្លុំ ត្រូវនៅត្រង់ខាងលើកំភួនដៃ)", អង្គនេះ នៅត្រង់អឌ្ឍមណ្ឌលៈនៃខណ្ឌ ២ ខាងក្រៅគេបំផុត ។ រួមត្រូវជាចីវរមានអង្គ ៩ ។ ចីវរមានអង្គ ៩ ដូច្នេះ ទើបត្រឹមត្រូវតាមពុទ្ធានុញ្ញាត ។ ចីវរទាំង ៣ គឺ សង្ឃាដី, ចីពរ, ស្បង់ ត្រូវធ្វើឲ្យប្រកបដោយអង្គ ៩ នេះដូចគ្នា វៀរលែងតែសំពត់ៗៈព្រោះធ្វើមិនគ្រាន់ ។ —